

Sustainable Rice Platform

វេទិកាដំណាំស្រូវប្រកបដោយនិរន្តរភាព

# ស្តង់ដាផលិតកម្មដំណាំស្រូវប្រកបដោយនិរន្តរភាព

Sustainable Rice Platform

# Standard for Sustainable Rice Cultivation

Version 2.1
January 2020
www.sustainablerice.org

## ១. សេចក្ដីផ្ដើម

នៅឆ្នាំ២០១៥ វេទិកាស្រូវប្រកបដោយនិរន្តរភាព (Sustainable Rice Platform) បានដាក់ចេញនូវស្តង់ដារដំបូងគេក្នុងពិភពលោកសម្រាប់ការដាំដុះស្រូវប្រកបដោយនិរន្តរភាព រួមជាមួយនឹងសំណុំសូចនាករនៃការអនុវត្តជាច្រើន ដើម្បីអនុញ្ញាតឱ្យមានការដាក់ពិន្ទុនិងប្រៀបធៀបអំពីនិរន្តរភាពនៃប្រព័ន្ធផលិតកម្មដំណាំស្រូវផ្សេងៗទៀត។ ឧបករណ៍នៃសូចនាករទាំងនេះអាចប្រើជានិយមន័យសម្រាប់ការងារផលិតកម្មស្រូវប្រកបដោយនិរន្តរភាព និងសម្រាប់វាស់វែងនូវគុណភាពផលិតកម្មនៃការប្រើប្រាស់ស្តង់ដារដែលសមស្របឬមិនសមស្របទៅនឹងផលិតកម្មស្រូវប្រកបដោយនិរន្តរភាព(SRP)។

ដើម្បីមានលទ្ធភាពត្រួតពិនិត្យដំណើរការនិងផលប៉ះពាល់នៃការអនុវត្ត វេទិកាដំណាំស្រូវប្រកបដោយនិរន្តរភាព(SRP)បានផ្ដល់ឱ្យអ្នករៀបចំគោលនយោបាយនិងអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងខ្សែច្រវ៉ាក់ផលិតកម្មដំណាំស្រូវពិភពលោក នូវបណ្ដុំនៃឧបករណ៍សម្រាប់ជួយសម្រួលដល់ការទទួលយកយ៉ាងទូលំទូលាយនៃការអនុវត្តល្អប្រកបដោយនិរន្តរភាពក្នុងវិស័យស្រូវអង្ករពិភពលោក ដែលឧបករណ៍ទាំងនេះមានទំនាក់ទំនងគ្នាដូចខាងក្រោម៖

១. ស្តង់ដារ SRP សម្រាប់ការដាំដុះស្រូវប្រកបដោយនិរន្តរភាព

២- សូចនាករនៃការអនុវត្ត SRP សម្រាប់ការដាំដុះស្រូវប្រកបដោយនិរន្តរភាព

៣- គ្រោងការធានារ៉ាប់រង SRP ។

ស្តង់ដារ SRP សម្រាប់ការដាំដុះស្រូវប្រកបដោយនិរន្តរភាពផ្តល់នូវក្របខ័ណ្ឌបទដ្ឋានជាមូលដ្ឋានសម្រាប់ការគាំទ្រចំពោះការអនុវត្តប្រកបដោយនិរន្តរភាពនៅក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ស្រូវ។ តាមរយៈការអភិវឌ្ឍន៍និងដំណើរការត្រួតពិនិត្យឡើងវិញ ភាគីពាក់ព័ន្ធនានាបានសង្កត់ធ្ងន់លើសារសំខាន់នៃការរក្សាទុកនូវស្តង់ដារជាឧបករណ៍ដែលមានលក្ខណៈសង្ខេប និងបានរួមបញ្ចូលគ្រប់ផ្នែកក្នុងផលិតកម្មសម្រាប់អ្នកអនុវត្តនិងទទួលយកទៅអនុវត្តបានយ៉ាងទូលំទូលាយលើការអនុវត្តល្អប្រកបដោយនិរន្តរភាពនិងភាពវៃឆ្លាតជាមួយនឹងការបម្រែបម្រួលអាកាសធាតុ ក្នុងចំណោមកសិករដាំដុះស្រូវខ្នាតតូច។ SRP បានចេញស្តង់ដារ SRP (កំណែ ២.០) ក្នុងខែមករាឆ្នាំ ២០១៩ ដែលមាន ៤១ លក្ខខណ្ឌតម្រូវ ហើយរៀបចំឡើងក្រោមប្រធានបទសំខាន់ៗចំនួន៨ផ្នែក។ កំណែ ២.១ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅខែមករាឆ្នាំ ២០២០ ។

សូចនាករនៃការអនុវត្ត SRP សម្រាប់ការដាំដុះស្រូវប្រកបដោយនិរន្តរភាពអនុញ្ញាតឱ្យមានការវាស់វែងផ្នែកបរិមាណ និងការវាយតំលៃផលប៉ះពាល់នៃនិរន្តរភាពលើការទទួលយកនូវការអនុវត្តដែលបានណែនាំនៅកម្រិតកសិដ្ឋាន។ សូចនាករនៃការអនុវត្តអាចឱ្យដៃគូអនុវត្ត និងអ្នកស្រាវជ្រាវប្រមូលទិន្នន័យគោល និងទំនាក់ទំនងនៃលទ្ធផលនៅកម្រិតកសិដ្ឋាន ដោយស្របតាមសូចនាករទាំង១២។ សូចនាករនៃការអនុវត្ត SRP (កំណែ ១.០) ត្រូវបានចេញផ្សាយនៅក្នុងខែមេសាឆ្នាំ២០១៥។ SRP បានត្រួតពិនិត្យឡើងវិញ និងកែសម្រួលក្នុងឆ្នាំ២០១៨ និងបានចេញផ្សាយកំណែ ២.០ នៅខែមករាឆ្នាំ២០១៩ ហើយកំណែ ២.១ ត្រូវបានដាក់ឱ្យដំណើរការនៅខែមករាឆ្នាំ២០២០ ។

គ្រោងការណ៍ធានារ៉ាប់រង SRP អនុញ្ញាតឱ្យតួអង្គក្នុងវិស័យខ្សែច្រវ៉ាក់តម្លៃស្រូវបង្ហាញពីការអនុលោមតាមស្តង់ដារ SRP ក៏ដូចជាផលប៉ះពាល់ដូចដែលបានវាស់ដោយសូចនាករនៃការអនុវត្ត SRP។ គ្រោងការណ៍នេះផ្តល់នូវការធានាចំនួន៣កម្រិត ដើម្បីឱ្យត្រូវនឹងបែបផែននៃផលិតកម្ម និងរួមបញ្ចូលនូវការចុះឈ្មោះកសិករ

នៅក្នុងបណ្តុំទិន្នន័យគោលរបស់ SRP ការវាយតំលៃដោយខ្លួនឯង និងការផ្ទៀងផ្ទាត់ក្រុមកសិករដែលត្រូវធ្វើឡើងតាមរយៈប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ការបញ្ជាក់ និងវិញ្ញាបនបត្រទទួលស្គាល់ពីអ្នកខាងក្រៅជាជម្រើសបន្ថែម។ អ្នកផ្តល់សេវាកម្មធានាអះអាងដែលទទួលស្គាល់ជាសកល (GLOBALG.A.P ) ត្រួតពិនិត្យ និងគ្រប់គ្រងការអនុវត្តនៃគ្រោងការណ៍។ ការធានារបស់គ្រោងការណ៍ SRP ត្រូវបានដាក់ឱ្យដំណើរការនៅឆ្នាំ ២០១៩ ដែលបានឆ្លងកាត់ដំណើរការបង្កើតដោយក្រុមការងាររបស់ SRP ដែលធ្វើការផ្នែកគាំទ្រកសិករ ការវាស់ស្ទង់លទ្ធផល និងធានារ៉ាប់រង ។

## ២. វិសាលភាពនៃស្តង់ដារ SRP សម្រាប់ដាំណាំស្រូវប្រកបដោយនិរន្តរភាព

បទដ្ឋាន SRP ដាក់ឱ្យអនុវត្តនៅគ្រប់ដំណើការក្នុងកសិដ្ឋាននៃផលិតកម្មដំណាំស្រូវ ដោយរាប់គិតចាប់ពីពេលរៀបចំដីរហូតដល់ក្រោយពេលប្រមូលផលនិងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់កសិករផងដែរ។ បទដ្ឋាន SRP អាចត្រូវបានយកទៅអនុវត្តដោយកសិករជាបុគ្គល ក្រុមអាជីវកម្មខ្នាតតូច ឬកសិដ្ឋានខ្នាតធំ ហើយផ្តោតទៅលើការធានានូវភាពទាក់ទងគ្នា ភាពប្រតិបត្តិ និងផលប៉ះពាល់ ជាពិសេសកសិករខ្នាតតូចនៅប្រទេសកំពុងអភិវឌ្ឍន៍។

ប្រសិនបើបទដ្ឋាននេះត្រូវបានយកទៅអនុវត្តជាមួយនឹងក្រុមកសិករខ្នាតតូច នេះស្នើឲ្យមានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង (IMS) មួយ ដើម្បីគាំទ្រកសិករក្នុងការអនុវត្តស្តង់ដារនេះ វាស់វែងលទ្ធផល និងកំណត់វិធីសាស្ត្រសម្រាប់ការកែលំអការអនុវត្តបន្តទៀត។

វាពិតជាមានសារៈសំខាន់ណាស់ក្នុងការការពារសេចក្តីសុច្ចរិត និងលក្ខខណ្ឌស្នូលរបស់ស្តង់ដារ SRP ព្រមទាំងធ្វើឱ្យធំទូទាយនិងមានភាពទាក់ទងដែលអាចអនុវត្តបានជាក់ស្តែង ស្របនឹងបរិបទចម្រុះបែបរបស់ប្រទេសនីមួយៗ រួមមាន ប្រព័ន្ធផលិតកម្ម ក្សេត្រសាស្ត្របរិស្ថាន ស្ថានភាពអេកូឡូស៊ីសង្គម និងក្របខណ្ឌច្បាប់ ឬបទបញ្ញត្តិផ្សេងៗ។ ខណៈដែលស្តង់ដារនេះផ្តល់ការណែនាំជាលក្ខណៈបទដ្ឋានសម្រាប់ប្រតិបត្តិ អ្នកអនុវត្តអាចត្រូវការការណែនាំដែលទាក់ទងនឹងការអនុវត្តនៅក្នុងមូលដ្ឋានអំពីអនុសាសន៍សមស្របនៃការអនុវត្តល្អ ដែលស្របនឹងលក្ខខណ្ឌតម្រូវរបស់ស្តង់ដារនេះ។ ជារួម គោលការណែនាំជាភាសាជាតិអាចត្រូវបានបង្កើតឡើង ដើម្បីសម្រួលដល់ស្តង់ដារសកល (Global Standard) និងការអនុវត្តនៅទីវាលក្នុងមូលដ្ឋាន។

## ៣. គោលការណ៍ប្រតិបត្តនិងសូចនាករសម្រាប់វាស់វែងស្តង់ដារ SRP

ដើម្បីទទួលបាននូវការទទួលស្គាល់នូវគុណភាពស្តង់ដារផលិតកម្មដំណាំស្រូវប្រកបដោយនិរន្តរភាព (SRP) មានសកម្មភាពដែលត្រូវអនុវត្តចំនួន៨ប្រធានបទ តម្រូវការចំនួន៤១ និងសូចនាករសម្រាប់វាស់វែងមានចំនួន១២ ដែលជាលក្ខខណ្ឌតម្រូវ មានដូចខាងក្រោមនេះ៖

| ការគ្រប់គ្រងកសិដ្ឋាន | សកម្មភាពមុនពេលដាំដុះ | ការប្រើប្រាស់ទឹក | ការគ្រប់គ្រងសារធាតុចិញ្ចឹម |
|---|---|---|---|
| - ប្រតិទិនដាំដុះដំណាំ<br>- ការកត់ត្រា<br>- ការបណ្តុះបណ្តាល | - លោហៈធ្ងន់<br>- ជាតិប្រៃនៃដី<br>- ការទន្ទ្រានដី និងដីរចម្រុះ<br>- ប្រភេទពាតត្បាត<br>- ការកៀរពង្រាបដី<br>- ការប្រើប្រាស់គ្រាប់ពូជមានគុណភាព | - ការគ្រប់គ្រងទឹក<br>- ប្រព័ន្ធស្រោចស្រពកម្រិតសហគមន៍<br>- គុណភាពទឹកប្រើប្រាស់<br>- ការទាញយកទឹកក្រោមដី<br>- ការបង្ហូរទឹកចេញ | - ការគ្រប់គ្រងសារធាតុចិញ្ចឹម ( សរីរាង្គ និងអសរីរាង្គ )<br>- ការប្រើប្រាស់ជីសរីរាង្គ<br>- ការប្រើប្រាស់ជីអសរីរាង្គ |
| **វិធានការចម្រុះគ្រប់គ្រងដំណាំ** | **ការប្រមូលផល និងក្រោយពេលប្រមូលផល** | **សុខភាព និងសុវត្ថិភាព** | **សិទ្ធិការងារ** |
| - ស្មៅចង្រៃ<br>- សត្វល្អិត<br>- ជំងឺ<br>- សិប្បីសត្វ<br>- កណ្តុរ<br>- បក្សី | - កំណត់ពេលវេលាប្រមូលផល<br>- ឧបករណ៍ និងបរិក្ខារ<br>- ពេលវេលាហាលសម្ងួត<br>- បច្ចេកទេសហាលសម្ងួត<br>- ការទុកដាក់ស្រូវ<br>- ការគ្រប់គ្រងជញ្ជាំង ការគ្រប់គ្រងចំបើង | - ការណែនាំអំពីសុវត្ថិភាព<br>- ឧបករណ៍ និងបរិក្ខារ<br>- ការបណ្តុះបណ្តាលអ្នកប្រើប្រាស់ថ្នាំកសិកម្ម<br>- សម្ភារការពារខ្លួន<br>- ការលាងសម្អាតនិងផ្លាស់ប្តូរ<br>- បម្រាបអ្នកប្រើប្រាស់ថ្នាំកសិកម្ម<br>- ពេលវេលាចូលស្រែ<br>- ការទុកដាក់ថ្នាំកសិកម្ម និងជាតិគីមី<br>- ការបោះចោលសំបកថ្នាំកសិកម្ម | - ពលកម្មកុមារ<br>- ការងារគ្រោះថ្នាក់<br>- ការអប់រំ<br>- ពលកម្មដោយបង្ខំ<br>- ការរើសអើង<br>- សេរីភាពសហគមន៍<br>- ប្រាក់ឈ្នួល |

លក្ខខណ្ឌតម្រូវនីមួយៗនៃស្តង់ដារ ត្រូវបានបង្កើតឡើងក្នុងគោលបំណងឱ្យសម្រេចបាននូវសូចនាករនៃការអនុវត្តផលិតកម្មដំណាំស្រូវប្រកបដោយនិរន្តរភាព(SRP)។ ការភ្ជាប់គ្នារវាងលក្ខខណ្ឌតម្រូវក្នុងស្តង់ដារ និងសូចនាករនៃការអនុវត្ត(តារាងទី១)។ ទំនាក់ទំនងនេះត្រូវបានបង្កើតដោយបង្ហាញយ៉ាងច្បាស់នូវផលប៉ះពាល់ក្នុងតារាងជួរឈរបស់ស្តង់ដារ។

| **ស្តង់ដារ** SRP | **សូចនាករនៃការអនុវត្ត** SRP | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រាក់កម្រៃ ចំណេញសុទ្ធ | ផលិតភាពការងារ | ទិន្នផល | ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក | ប្រសិទ្ធភាពនៃការប្រើប្រាស់សារធាតុចិញ្ចឹម (អាសូត) | ប្រសិទ្ធភាពនៃការប្រើប្រាស់សារធាតុចិញ្ចឹម (ផូស្វាត) | ជីវចម្រុះ | ការបំភាយឧស្ម័នផ្ទះកញ្ចក់ | សុវត្ថិភាពអាហារ | សុភាព និងសុវត្ថិភាពកម្មករ | ពលកម្មកុមារ និងការចូលរួមរបស់យុវជន | ការលើកកំពស់ស្ត្រី |
| **លក្ខខណ្ឌតម្រូវ** | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១. ប្រតិទិនដាំដុះ | × | | × | | | | | | | | | |
| ២. ការកត់ត្រា | × | | × | | | | | | | | | |
| ៣. ការបណ្តុះបណ្តាល | × | × | × | × | × | × | × | × | × | × | × | × |
| ៤. លោហៈធ្ងន់ | | | | | | | | | × | | | |
| ៥. សារធាតុប្រៃក្នុងដី | × | | × | × | | | | | | | | |
| ៦. ការទន្ទ្រានដីព្រៃ& បំផ្លាញជីវៈចំរុះ | | | | | | | × | × | | | | |
| ៧. ប្រភេទពូជដែលមានលក្ខណៈរាតត្បាត | | | | | | | × | | | | | |
| ៨. ការកៀរពង្រាបដី | × | | × | × | | | × | | | | | |
| ៩. ការប្រើប្រាស់គ្រាប់ពូជស្រូវគុណភាពល្អ | × | | × | | | | | | | | | |
| ១០. ការគ្រប់គ្រងទឹក | × | | × | × | | | | × | | | | |
| ១១. ប្រព័ន្ធស្រោចស្រពកម្រិតសហគមន៍ | | | | × | | | | | | | | |
| ១២. គុណភាពទឹកបញ្ចូលស្រែ | | | | × | | | | | × | | | |
| ១៣. ការទាញយកទឹកពីក្រោមដី | | | | × | | | | | | | | |
| ១៤. ការបញ្ចេញទឹកចេញពីស្រែ | | | | × | | | × | | | | | |
| ១៥. ការគ្រប់គ្រងសារធាតុចិញ្ចឹម (សរីរាង្គ & អសរីរាង្គ | × | | × | | × | × | × | × | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៦. ការប្រើប្រាស់ជីសរីរាង្គ | × | | × | | × | × | | × | | | | |
| ១៧. ការប្រើប្រាស់ជីអសរីរាង្គ | × | | × | | × | × | | × | | | | |
| ១៨. វិធានចម្រុះគ្រប់គ្រងដំណាំ | × | | × | | | | × | | × | | | |
| ១៩.ការកំណត់ពេលវេលាប្រមូលផល | × | | × | | | | | | × | | | |
| ២០. ឧបករណ៍ប្រមូលផល | | | | | | | | | × | | | |
| ២១. ពេលវេលាសម្ងួត | × | | × | | | | | × | | | | |
| ២២. បច្ចេកទេសសម្ងួត | × | | × | | | | | | × | | | |
| ២៣. ការទុកដាក់ស្រូវ | × | | × | | | | | | × | | | |
| ២៤. ការគ្រប់គ្រងជញ្ជាំង | | | | | × | × | | × | | | | |
| ២៥. ការគ្រប់គ្រងចំបើង | | | | | × | × | | × | | | | |
| ២៦. ការណែនាំអំពីសុវត្ថិភាព | | | | | | | | | | × | | |
| ២៧. សម្ភារ និងឧបករណ៍ | | | | | | | | | | × | | |
| ២៨. ការបណ្ដុះបណ្ដាលអ្នកប្រើប្រាស់ថ្នាំពុល | | | | | | | | | | × | | |
| ២៩. សម្ភារការពារខ្លួន | | | | | | | | | | × | | |
| ៣០. ការប្ដូរ និងសម្អាតសម្ភារ | | | | | | | | | | × | | |
| ៣១. បម្រាម | | | | | | | | | | × | | |
| ៣២. ពេលវេលាចូលស្រែ | | | | | | | | | | × | | |
| ៣៣. ការទុកដាក់ថ្នាំកសិកម្ម និងជាតិគីមី | | | | | | | | | × | × | | |
| ៣៤. ការបោះចោលថ្នាំកសិកម្ម | | | | | | | | | | × | | |
| ៣៥. ពលកម្មកុមារ | | | | | | | | | | | × | |
| ៣៦. ការងារគ្រោះថ្នាក់ | | | | | | | | | | | × | |
| ៣៧. ការអប់រំ | | | | | | | | | | | × | |
| ៣៨. ពលកម្មបង្ខំ | | | | | | | | | | | | |
| ៣៩. ការរើសអើងការងារ | | | | | | | | | | | | × |
| ៤០. សេរីភាពសហគមន៍ | | | | | | | | | | | | × |
| ៤១. ប្រាក់ឈ្នួល | | | | | | | | | | | | × |

## **ការដាក់ពិន្ទុ**

បទដ្ឋានអនុញ្ញាតឲ្យមានការអនុវត្តជាជំហានៗ ដើម្បីលើកទឹកចិត្តនិងផ្តល់រង្វាន់ទៅតាមការអនុវត្តន៍យ៉ាងពេញលេញ។ លក្ខខណ្ឌតម្រូវទាំងអស់មានកម្រិតនៃការអនុវត្តបាន មានច្រើន ដែលធ្វើឱ្យស្តង់ដារនេះអាចប្រើប្រាស់សម្រាប់ការវាយតម្លៃផង និងជាឧបករណ៍កែលម្អដែលមានទិសដៅឆ្ពោះទៅលើកកម្ពស់ការទទួលយករបស់កសិករផង។ កម្រិតខុសៗគ្នាទាំងនេះត្រូវបានអភិវឌ្ឍឡើងដោយមានការទទួលស្គាល់យ៉ាងពេញលេញថាការកែលម្អលទ្ធផលការងាររបស់កសិករត្រូវការពេលវេលាហើយអាចជាដំណើរការដ៏លំបាកមួយ។ ការធ្វើឲ្យមានការអនុវត្តន៍ការងារច្រើនកម្រិត អាចបង្ហាញពីដំណើរការកែលម្អនិងផ្តល់ការទទួលស្គាល់ចំពោះដំណាក់កាលកែលម្អនីមួយៗដោយពិន្ទុកាន់តែខ្ពស់ជាងមុន។

កម្រិតនៃការអនុវត្តការងារនីមួយៗឆ្លើយតបទៅនឹងចំនួនពិន្ទុ។ កម្រិតការអនុវត្តការងារខ្ពស់បំផុតនៅក្នុងលក្ខខណ្ឌតម្រូវភាគច្រើនមាន៣ពិន្ទុ។ លក្ខខណ្ឌតម្រូវមួយចំនួនទៀតមានកម្រិតអនុវត្តការងារបន្ថែមមធ្យមមាន១ពិន្ទុ ឬ២ពិន្ទុ។ លក្ខខណ្ឌតម្រូវទាំងអស់ត្រូវបានបង្ហាញកម្រិតទាបបំផុតនៃការអនុវត្តការងារត្រឹមសូន្យពិន្ទុ។ មានករណីលើកលែងមួយចំនួនចំពោះពិន្ទុអតិបរមាក្នុងតម្រូវការនីមួយៗ។ តម្រូវការទី១៥ស្តីពីការគ្រប់គ្រងសារធាតុចិញ្ចឹមមានពិន្ទុអតិបរមាចំនួន៦ពិន្ទុហើយតម្រូវការទាំងអស់នៅក្នុងផ្នែកសុខភាពនិងសុវត្ថិភាពមានពិន្ទុអតិបរមាចំនួន២ពិន្ទុ។ ការផ្លាស់ប្តូរទាំងនេះធ្វើឡើងដើម្បីទទួលបានរង្វាស់តុល្យភាពមួយ ទៅតាមភាពខុសគ្នារបស់សកម្មភាពនីមួយៗ។ រង្វាស់ទៅតាមសកម្មភាពនីមួយៗបង្ហាញនៅក្នុងរូបភាពទី២។




**រូបភាពទី២៖ រង្វាស់នៃបទដ្ឋាន SRP តាមប្រភេទសកម្មភាព**

ពិន្ទុសរុបនៃការអនុវត្តលើបទដ្ឋាននេះត្រូវបានបង្ហាញកម្រិតពី០-១០០។ ពិន្ទុនេះគឺផ្អែកលើចំនួនពិន្ទុសរុបដែលកសិករម្នាក់ទទួលបានចែកនឹងចំនួនពិន្ទុអតិបរមាដែលអាចទទួលបាន (១៣២) គុណនឹង ១០០។

$$\text{ពិន្ទុ (០ – ១០០)} = \frac{\text{ពិន្ទុសរុបនៃការអនុវត្តស្តង់ដារ SRP}}{\text{ចំនួនពិន្ទុអតិបរមាដែលអាចទទួលបាន}} \times ១០០$$

លក្ខខណ្ឌតម្រូវមួយចំនួនអាចមិនត្រូវបានអនុវត្តនៅក្នុងលក្ខខណ្ឌមួយចំនួន ហើយមិនត្រូវបានរាប់

បញ្ចូលក្នុងការដាក់ពិន្ទុនោះទេ។ ចំណុចមិនអាចអនុវត្តបានអាចមានទៅតាមករណីដូចខាងក្រោម៖

- ពេលកសិករធ្វើស្រែពឹងផ្អែកទឹកភ្លៀង (គ្មានប្រព័ន្ធស្រោចស្រព) លក្ខខណ្ឌតម្រូវទី ១១,១២, ១៣, និង ១៤ មិនត្រូវរាប់បញ្ចូលឡើយ។
- ពេលកសិករមិនសម្ងួតស្រូវរបស់គាត់ដោយខ្លួនឯង លក្ខខណ្ឌតម្រូវទី មិនត្រូវរាប់បញ្ចូលឡើយ។
- ពេលកសិករមិនទុកដាក់ស្រូវរបស់គាត់ លក្ខខណ្ឌតម្រូវទី ២៣ មិនត្រូវរាប់បញ្ចូលឡើយ។
- ពេលកសិករគ្មានកូនអាយុក្រោម ១៨ ឆ្នាំ ធ្វើស្រែទេនោះ លក្ខខណ្ឌតម្រូវទី ៣៦ មិនត្រូវរាប់ បញ្ចូលឡើយ។
- ពេលកសិករគ្មានកូនក្នុងវ័យសិក្សាទេនោះ លក្ខខណ្ឌតម្រូវទី ៣៧ មិនត្រូវរាប់ បញ្ចូលឡើយ។
- ពេលកសិករគ្មានជួលកម្មករទេនោះ លក្ខខណ្ឌតម្រូវទី ៣៨, ៣៩, ៤០, និង ៤១ មិនត្រូវរាប់ បញ្ចូលឡើយ។

**អំណះអំណាង**

ឈ្មោះ និងផ្លាកសញ្ញារបស់ SRP ត្រូវបានចុះបញ្ជីជាផ្លាកយីហោពាណិជ្ជកម្ម និងការប្រើប្រាស់ផ្សេងៗទៀត ដូចជាការធានាអះអាងលើបទដ្ឋាន SRP ចាំបាច់ត្រូវគោរពយ៉ាងពេញលេញទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានចែងនៅក្នុងផ្នែកធានារ៉ាប់រងរបស់ SRP និងគោលការណ៍ណែនាំស្តីពីការទំនាក់ទំនង និងការទាមទារសំណាងរបស់ SRP។

ស្តង់ដារSRP អនុញ្ញាតឱ្យមានការវាយតម្លៃកសិករ ដោយយោងទៅតាមកម្រិតនៃការអនុវត្តប្រកបដោយនិរន្តរភាពក្នុងការដាំដុះដំណាំស្រូវ។ នេះគាំទ្រគោលបំណងពីរ៖

***១. កំណត់និយមន័យអ្វីដែលហៅថានិរន្តរភាព***

បទដ្ឋាន SRP អនុញ្ញាតឲ្យអ្នកប្រើប្រាស់អាចអះអាងថាស្រូវ "ត្រូវបានដាំដុះប្រកបដោយនិរន្តរភាព"។ ការអះអាងបែបនេះត្រូវតែឆ្លើយតបនឹងពិន្ទុសរុបទទួលបានខ្ពស់បំផុតដែលបានផ្ទៀងផ្ទាត់។ បទដ្ឋាន SRP បានកំណត់ពីពិន្ទុអប្បបរមា និងកម្រិតការអនុវត្តចាំបាច់ (កម្រិតចាប់ផ្តើម: thresholds) ដែលត្រូវសម្រេចនូវគ្រប់លក្ខខណ្ឌតម្រូវ ដើម្បីឆ្លើយតបទៅនឹងការអះអាងថា" ស្រូវដាំដុះប្រកបដោយនិរន្តរភាព"។

***២. ជំរុញការកែលម្អឱ្យប្រសើរឡើង***

SRP ទទួលស្គាល់ថាកសិករជាច្រើនបានដើរលើផ្លូវនៃការងារឆ្ពោះទៅរកការដាំដុះស្រូវប្រកបដោយនិរន្តរភាព ហើយថាការកែលម្អការអនុវត្តប្រកបដោយនិរន្តរភាពគឺជាដំណើរការបំពេញបន្ថែម។ SRP បានកំណត់ពីពិន្ទុអប្បបរមា និងកម្រិតការអនុវត្តចាំបាច់ (កម្រិតពិន្ទុចាប់ផ្តើម: thresholds) ដែលត្រូវសម្រេចបាន ដើម្បីអះអាងថា "កំពុងធ្វើការដាំដុះស្រូវឆ្ពោះទៅរកការដាំដុះស្រូវប្រកបដោយនិរន្តរភាព" ។ ការកំណត់នៃកម្រិតពិន្ទុចាប់ផ្តើមនេះរួមមានលក្ខខណ្ឌតម្រូវទី៤, ១៨.១ ១៨.២, ២៣, ២៩, ៣៣, ៣៤, ៣៥ និង៣៦ ដែលទាក់ទងនឹងសុខភាពកសិករ និងសុវត្ថិភាពអាហារ។ ការធ្វើឱ្យល្អប្រសើរឡើងជាបន្តបន្ទាប់គួរតែត្រូវបានបង្ហាញ ដើម្បីរក្សាការអះអាងថានិរន្តរភាព ដោយតួអង្គក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់។

កម្រិតនៃការអនុវត្តចាំបាច់ (កម្រិតពិន្ទុចាប់ផ្តើម threshold) សម្រាប់លក្ខខណ្ឌតម្រូវនីមួយៗនៅក្នុងស្តង់ដារ SRP ត្រូវបានបញ្ជាក់ដោយសញ្ញាផ្កាយ (*) នៅជាប់នឹងកម្រិតនៃការអនុវត្ត។ ការអះអាងនៃការដាំដុះស្រូវប្រកបដោយនិរន្តរភាពអាចធ្វើទៅបានលុះត្រាតែកម្រិតពិន្ទុចាប់ផ្តើមចាំបាច់ត្រូវបានបំពេញ ហើយទទួលបាន **ពិន្ទុអប្បបរមា ៩០%** ។ ស្របតាមគោលបំណងទាំងនេះ ស្តង់ដារ SRP អនុញ្ញាតឱ្យមានការអះអាងដូច

ខាងក្រោម។ SRP បានកំណត់លក្ខខណ្ឌត្រូវតែបំពេញតាមកម្រិតនៃការអះអាងនីមួយៗ (តារាងទី២)។

**តារាងទី ២៖ ការអះអាង និងលក្ខខណ្ឌ**

| ការអះអាង | លក្ខខណ្ឌបំពេញដំបូងលើកម្រិតអះអាងនេះ | លក្ខខណ្ឌបំពេញដំបូងលើកម្រិតអះអាងនេះនៅឆ្នាំបន្ទាប់ |
| --- | --- | --- |
| ធ្វើការឆ្ពោះទៅរកការដាំដុះស្រូវប្រកបដោយនិរន្តរភាព | ✓ បានពិន្ទុយ៉ាងហោចណាស់ ៣៣ពិន្ទុ លើ ១០០ពិន្ទុ<br>✓ បានបំពេញតាមកម្រិតនៃការអនុវត្តចាំបាច់ (Threshold) សម្រាប់លក្ខខណ្ឌតម្រូវ ៤, ១៨.១-១៨.៥, ២៣, ២៩, ៣៣, ៣៤, ៣៥ និង ៣៦ (ប្រសិនបើលក្ខខណ្ឌតម្រូវអាចអនុវត្តបាន) | ✓ បន្តបំពេញតាមលក្ខខណ្ឌដែលបានបញ្ជាក់នៅក្នុងជួរឈរខាងឆ្វេង<br>✓ ធ្វើឱ្យប្រសើរឡើងនូវកម្រិតនៃការអនុវត្តដែលបានបញ្ជាក់នៅក្នុងជួរឈរខាងឆ្វេង |
| ស្រូវបានដាំដុះប្រកបដោយនិរន្តរភាព | ✓ បានពិន្ទុយ៉ាងហោចណាស់ ៩០ ពិន្ទុ លើ ១០០ ពិន្ទុ<br>✓ បានបំពេញតាមកម្រិតនៃការអនុវត្តចាំបាច់លើគ្រប់លក្ខខណ្ឌតម្រូវដែលអាចអនុវត្តបាន | ✓ រក្សាកម្រិតនៃការអនុវត្ត ដែលបានបញ្ជាក់នៅក្នុងជួរឈរខាងឆ្វេង |

កសិករមានសេរីភាពក្នុងការជ្រើសរើសនូវលក្ខខណ្ឌតម្រូវអ្វីដែលត្រូវបានប្រើ ដើម្បីបង្ហាញពីការកែលម្អជាបន្តបន្ទាប់ និងភ្ជាប់គម្លាតទៅនឹងកម្រិតអះអាងបន្ទាប់។ រូបភាពទី ៣ បង្ហាញពីការដាក់ពិន្ទុ និងយន្តការអះអាងដូចខាងក្រោម។




រូបភាពទី ៣៖ ការដាក់ពិន្ទុ និងការអះអាងក្នុងបទដ្ឋាន SRP

ផលិតកម្មដំណាំស្រូវប្រកបដោយនិរន្តរភាព(SRP) អនុញ្ញាឱ្យមានការអភិវឌ្ឍការបកស្រាយសមស្រប

ផ្សេងៗជាថ្នាក់ជាតិ ដើម្បីផ្តល់ការបន្ថែមលក្ខណៈបច្ចេកទេសយោងទៅតាមក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិជាតិ ដែលពាក់ព័ន្ធ និងបរិបទនៃផលិតកម្មក្នុងស្រុក។ ទោះយ៉ាងណាក៏ដោយគោលការណ៍ណែនាំដែលបកប្រែភាសាជាតិរបស់(SRP) ត្រូវតែរក្សាប្រព័ន្ធផ្តល់ពិន្ទុ និងកម្រិតពិន្ទុនៃការអនុវត្តអប្បរមា (កម្រិតពិន្ទុចាប់ផ្តើមៈ thresholds) ដើម្បីធានានូវភាពស្មើគ្នានៃធានាអះអាង។

ការទំនាក់ទំនងណាមួយលើការធានាអះអាងត្រូវអនុវត្តតាមគ្រោងការណ៍ការធានារ៉ាប់រង SRP ( SRP Assurance Scheme) ដែលកំណត់ពីរបៀបដែលអ្នកធ្វើអាចវាស់វែងការអនុវត្ត បង្ហាញពីការធ្វើឱ្យល្អប្រសើរ និងប្រើស្លាកសញ្ញាពាណិជ្ជកម្ម SRP (ការធានាអះអាង ឬ និមិត្តសញ្ញា) ។ ការប្រើប្រាស់ឈ្មោះពាណិជ្ជកម្ម SRP ឬស្លាកសញ្ញាពាណិជ្ជកម្មត្រូវអនុវត្តតាមគោលការណ៍ណែនាំស្តីពីការទំនាក់ទំនង និងការធានាំអះអាងរបស់ SRP ហើយមានតែសមាជិក SRP និងអង្គការកសិករប៉ុណ្ណោះទទួលបានការយល់ព្រមលើការប្រើប្រាស់ស្លាកយីហោពាណិជ្ជកម្មសម្រាប់ធានាអះអាងបញ្ជាក់ ឬសេចក្តីថ្លែងការណ៍តម្លៃស្តីពីការអនុវត្ត ឬការកែលម្អឱ្យល្អប្រសើរដោយផ្អែកលើស្តង់ដារ SRP ។

## បញ្ជីនិយមន័យ

| | |
|---|---|
| ម្តងសើម និងម្តងស្ងួត (Alternative Wet and Dry) | ជាបច្ចេកទេសសន្សំសំចៃទឹកមួយ ដើម្បីកាត់បន្ថយការប្រើប្រាស់ទឹកនៅក្នុងស្រែ ដោយធ្វើការស្រោចស្រពជាចន្លោះៗ ដែលមានគម្លាតក្នុងចំនួនថ្ងៃជាក់លាក់ ដោយផ្អែកលើមូលដ្ឋាន SMP (សក្តានុពលម៉ាទ្រិចដី) ដោយប្រើ tensiometers ឬសក្តានុពលសំពាធដី (ប្រើប្រាស់បំពង់វាស់ទឹកក្នុងស្រែ) |
| ពលកម្មកុមារ (Childe labor) | កុមារចូលរួមក្នុងពលកម្មកុមារដែលមានគ្រោះថ្នាក់ ឬកុមារអាយុក្រោម ១៥ ឆ្នាំធ្វើការក្នុងកសិដ្ឋានពាណិ។ សកម្មភាពមិនមានគ្រោះថ្នាក់ដល់កម្មករវ័យក្មេងនៅលើកសិដ្ឋានគ្រួសារត្រូវបានដកចេញ។ |
| ផ្ទៃដីស្រោចស្រពបាន (Command area) | ផ្ទៃដីសរុបដែលអាចស្រោចស្រពដោយទទួលបានផលចំណេញបានតាមរយៈប្រព័ន្ធធារាសាស្ត្រ ឬមធ្យោបាយផ្សេងៗ ដោយមិនគិតពីដែនកំណត់នៃបរិមាណទឹកដែលមាន ហើយវារួមបញ្ចូលទាំងតំបន់ដែលមិនបានដាំដុះ (ឧទាហរណ៍ ស្រះ តំបន់លំនៅដ្ឋាន) |
| ប្រតិទិនដាំដុះ (Crop calendar) | ផែនការ និងកាលវិភាគដែលបានគ្រោង សម្រាប់រដូវកាលដាំដុះចាប់ពីការរៀបចំដីការដាំដុះ និងថែទាំដំណាំ រហូតដល់ប្រមូលផល និងស្តុកទុក។ ប្រតិទិនដំណាំអនុញ្ញាតឱ្យកសិកររៀបចំផែនការទិញ និងប្រើប្រាស់ជាតុចូល និងកំណត់តម្រូវការកំលាំងពលកម្មរៀបចំរកអ្នកម៉ៅការ និងរៀបចំសកម្មភាពផ្សេងៗទៀតសម្រាប់ការគ្រប់គ្រងកសិដ្ឋាន។ |
| ការដាំដំណាំបង្វិល (Crop rotation) | ការអនុវត្តនៃការដាំដំណាំជាស៊េរីនៅលើផ្ទៃដីតែមួយក្នុងរដូវកាលបន្តបន្ទាប់។ ការដាំដំណាំបង្វិលអាចមានរយៈពេលច្រើនជាងមួយឆ្នាំប្រសិនបើមានប្រភេទដំណាំច្រើនប្រភេទត្រូវបានរាប់បញ្ចូលក្នុងកាលវិភាគតាមលំដាប់លំដោយដែលចំណាយពេលលើសពីមួយឆ្នាំដើម្បីបញ្ចប់ (ឧទាហរណ៍ ការដាំបង្វិលនៃមុខដំណាំស្រូវ-អំពៅ ដែលអំពៅត្រូវបានដាំដុះក្នុងរយៈពេល ១២ ទៅ ១៨ ខែបន្ទាប់ពីដំណាំស្រូវ) ។ |
| រដូវដាំដុះ (Cropping season) | រយៈពេលនៃការដាំដំណាំតែមួយ។ ចំពោះដំណាំស្រូវ រដូវកាលដាំដុះជាទូទៅចាប់ផ្តើមតាំងពីការរៀបចំដី និងរួមបញ្ចូលទាំងការសាបគ្រាប់ពូជនៅក្នុងថ្នាល ឬដោយព្រោះគ្រាប់ផ្ទាល់នៅទីវាល និងបញ្ចប់បន្ទាប់ពីការប្រមូលផលរួច។ |
| ការកាប់បំផ្លាញព្រៃឈើ (Deforestation) | ជាការប្រែក្លាយដីព្រៃដោយមនុស្សទៅជាដីវាលធម្មតាគ្មានព្រៃ |
| ការដាំដោយគ្រាប់ផ្ទាល់ (Direct seeding) | ដំណើរការនៃការដាំដុះស្រូវដោយព្រោះគ្រាប់នៅលើដីស្រែជាជាងដោយស្ទូងកូនសំណាបពីថ្នាល។ ដំណាំអាចត្រូវបានព្រោះលើផ្ទៃដី (សើម ឬស្ងួត) ដាំគ្រាប់ពូជ ឬព្រោះគ្រាប់ និងលុបដីនៅពេលដែលសាបព្រួសរួចនៅលើដីដែលស្ងួត។ |
| ការបង្ហូរទឹកចេញ (Drainage) | ការហូរចេញនៃទឹកផ្នែកខាងលើ និងទឹកក្នុងដីដោយធម្មជាតិ ឬដោយសិប្បនិម្មិតពីទីវាល ឬតំបន់ទេសភាព។ |
| ដីស្ងួត (Dry land ) | ដីដែលមិនមានទឹកដក់ និងមិនមានទឹក។ |

| | |
|---|---|
| សេវាកម្មអេកូឡូស៊ី (Ecosystem services) | អត្ថប្រយោជន៍បង្កើត ឬផ្តល់ដោយប្រព័ន្ធអេកូឡូស៊ី ដែលរួមចំណែកដល់ជីវិត និងសុខុមាលភាពរបស់មនុស្ស។ សេវាកម្មអេកូឡូស៊ីត្រូវបានបែកជា ៤ក្រុមធំ ៗ គឺ១) ការផ្តល់ឱ្យ (Provisioning) ដូចជាផលិតផលអាហារ និងទឹក ២) ការរក្សា (Regulating) ដូចជាការគ្រប់គ្រងអាកាសធាតុ និងជំងឺ ៣) ការគាំទ្រ(Supporting) ដូចជាវដ្តសារធាតុចិញ្ចឹម និងផលិតកម្មអុកស៊ីសែន។ និង៤) វប្បធម៌ (Cultural) ដូចជាអត្ថប្រយោជន៍ខាងផ្លូវអារម្មណ៍ និងការកំសាន្ត។ |
| ធ្វើឱ្យទៅជាដីល្បប់ (Effective puddling) | ដំណើរការភ្ជួរប្រែដីដែលមានទឹកទៅជាដីភក់ទន់គ្មានរចនាសម្ព័ន្ធដី។ ប្រសិទ្ធភាពត្រូវបានវាស់វែងដោយការថយចុះនៅរដូវកាលដាំដុះស្រូវ ។ |
| កសិដ្ឋាន (Farm) | ដី និងគ្រឿងបរិក្ខារប្រើប្រាស់សម្រាប់សកម្មភាពផលិតកម្មកសិកម្ម និងកែច្នៃ ដែលគ្រប់គ្រងដោយអង្គភាពតែមួយ និងប្រើប្រាស់នីតិវិធីប្រតិបត្តិការដូចគ្នា។ |
| កសិករ (Farmer) | បុគ្គលទាំងបុរស និងស្ត្រី (ឬអង្គការ) ទទួលខុសត្រូវលើការគ្រប់គ្រងកសិដ្ឋាន ឬដីកសិកម្ម។ |
| ក្រុមកសិករ (Farmer group or Group) | ជាក្រុមកសិករដែលចងក្រងឡើងនៅក្នុងសមាគមន៍ ឬសហគមន៍ ឬស្ថិតនៅក្រោមការគ្រប់គ្រងដោយអ្នកផ្គត់ផ្គង់ក្នុងខ្សែច្រវ៉ាក់ផលិតកម្មមួយ (ដូចជាម្ចាស់រោងម៉ាស៊ីន ឬអ្នកនាំចេញ ) ឬអង្គភាពដទៃទៀត។ |
| វិធានការចម្រុះគ្រប់គ្រងកត្តាចង្រៃ (IPM) | ជាវិធីសាស្ត្រគ្រប់គ្រងប្រព័ន្ធបរិស្ថានមួយ ដើម្បីឲ្យចំនួនកត្តាចង្រៃនៅក្រោមកម្រិតការបំផ្លិចបំផ្លាញដែលប៉ះពាល់ដល់សេដ្ឋកិច្ច ដោយកាត់បន្ថយគ្រោះថ្នាក់ដល់មនុស្ស សត្វ រុក្ខជាតិនិងបរិស្ថានឲ្យបានច្រើនបំផុត។ វិធីសាស្ត្រនេះ សម្រេចទៅបានតាមរយៈការចម្រុះបញ្ចូលគ្នានូវរាល់បច្ចេកទេសដែលមានប្រសិទ្ធភាពជាច្រើន ដូចជាការប្រើប្រាស់ពូជធន់ ការថែរក្សាសត្រូវពីធម្មជាតិដោយការកែលម្អជម្រក និងការកាត់បន្ថយ/ជៀសវាងការប្រើថ្នាំកសិកម្ម និងការកែប្រែការអនុវត្តន៍ក្នុងការដាំដុះ។ |
| ប្រភេទរាតត្បាត (Invasive species) | សត្វ រុក្ខជាតិ ឬសារពាង្គកាយដទៃទៀត ដែលនាំមកដោយមនុស្សចូលទៅក្នុងកន្លែងក្រៅពីជំរកធម្មជាតិរបស់ពួកវា ហើយប្រភេទទាំងនេះបានបង្កើត និងរីករាលដាល និងបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាននៅក្នុងប្រព័ន្ធអេកូឡូស៊ី និងប្រភេទពូជក្នុងស្រុក។ ប្រភេទពូជរាតត្បាតអាចជះឥទ្ធិពលអវិជ្ជមានដល់សុខភាពមនុស្ស សេដ្ឋកិច្ច (ឧទាហរណ៍ ទេសចរណ៍ កសិកម្ម) និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់។ ផលប៉ះពាល់ទាំងនេះអាចនឹងរំខានដំណើរការប្រព័ន្ធអេកូឡូស៊ី នាំឱ្យមានជំងឺដល់មនុស្ស ឬពពួកសត្វ និងពពួករុក្ខជាតិ និងធ្វើឱ្យបន្ថយចុះជីវៈចម្រុះ។ |
| ការស្រោចស្រព (Irrigation) | ប្រព័ន្ធក្នុងកសិដ្ឋានសម្រាប់ផ្គត់ផ្គង់ទឹកដល់ដី ឬដំណាំដែលត្រូវបានគ្រប់គ្រង និងប្រើប្រាស់ដោយមានការសម្របសម្រួលជាមួយតួអង្គសំខាន់ៗ (ឧទាហរណ៍ រដ្ឋាភិបាល អ្នកផ្តល់សេវាកម្ម សហគមន៍ និងកសិករ) នៅពេលណាដែលកសិករ ឬក្រុមកសិករប្រើប្រាស់ទឹក ។ |

| | |
|---|---|
| ប្រព័ន្ធផលិកម្មដោយការស្រោចស្រព-តំបន់លិចទឹក (Irrigated production system— flood-prone) | ជាប្រព័ន្ធកសិកម្ម ដែល ១) ការស្រោចស្រពត្រូវបានគ្រប់គ្រង ប្រើប្រាស់ដោយមានការសម្របសម្រួលជាមួយតួអង្គសំខាន់ៗ (ឧទាហរណ៍ រដ្ឋាភិបាល អ្នកផ្តល់សេវាកម្ម សហគមន៍ និងកសិករ) នៅពេលណាដែលកសិករ ឬក្រុមកសិករប្រើប្រាស់ទឹក និង ២) តំបន់ទាបដែលជន់លិចដោយទឹកទន្លេហូរឡើង ទឹកភ្លៀង ឬទឹកឡើង ជាតំបន់ដែលទឹកដក់នៅយូរបីសប្តាហ៍ ឬច្រើនជាងនេះ។ |
| ប្រព័ន្ធផលិកម្មដោយការស្រោចស្រព-តំបន់មិនលិចទឹក (Irrigated production system— not flood-prone) | ជាប្រព័ន្ធកសិកម្ម ដែល ១) ការស្រោចស្រពត្រូវបានគ្រប់គ្រង ប្រើប្រាស់ដោយមានការសម្របសម្រួលជាមួយតួអង្គសំខាន់ៗ (ឧទាហរណ៍ រដ្ឋាភិបាល អ្នកផ្តល់សេវាកម្ម សហគមន៍ និងកសិករ) នៅពេលណាដែលកសិករ ឬក្រុមកសិករប្រើប្រាស់ទឹក និង ២) តំបន់គ្រប់គ្រង និងធ្វើការស្រោចស្រពទឹកបានតាមបំណង។ |
| តំបន់ជីវចម្រុះសំខាន់ (Key Biodiversity Area) | បណ្តុំទិន្នន័យពិភពលោកនៃតំបន់ជីវចម្រុះសំខាន់ៗ ផ្ទុកទិន្នន័យអំពីតំបន់ជីវចម្រុះសំខាន់ៗ (KBAs)។ ទិន្នន័យនេះអាចប្រើប្រាស់សម្រាប់គាំទ្រការសម្រេចចិត្តជាយុទ្ធសាស្ត្រលើតំបន់ការពាររបស់រដ្ឋាភិបាល ឬសង្គមស៊ីវិល និងណែនាំអំពីការកំណត់ទីតាំងនៅក្រោមអនុសញ្ញាអន្តរជាតិ និងក្នុងការរៀបចំគោលនយោបាយ និងស្តង់ដារសម្រាប់វិស័យឯកជន។ ទិន្នន័យនេះត្រូវបានគ្រប់គ្រងដោយដៃគូរបស់ KBA ដែលជាលេខាធិការដ្ឋាន KBA ចូលរួមដោយអង្គការជីវិតសត្វស្លាបអន្តរជាតិ (BirdLife international) និង និងសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (International Union for Conservation of Nature)។ សូមមើលទិន្នន័យពិភពលោកនៃតំបន់ជីវចម្រុះសំខាន់ៗតាមរយៈ http://www:http://www.keybiodiversityareas.org/site/search |
| តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម (Non-application zones) | តំបន់មិនមែនជាគោលដៅ ខ្សែទឹក (រួមទាំងបណ្តាញធារាសាស្ត្រសំខាន់) ប្រឡាយបង្ហៀរតូច តំបន់ការពារ និងតំបន់ដែលមានចម្ងាយ ៥ ម៉ែត្រ ពីសកម្មភាពមនុស្ស (រួមមានសាលារៀន អគារ ផ្លូវថ្នល់ និងផ្លូវ)។ ការប្រើប្រាស់ថ្នាំកសិកម្ម (ជីវសាស្ត្រ និងគីមី) ត្រូវតែជៀសវាងនៅតំបន់ទាំងនេះ។ ដើម្បីប្រើប្រាស់លើតំបន់ដែលបានកំណត់ ថ្នាំកសិកម្មគួរតែត្រូវបានប្រើក្នុងលក្ខខណ្ឌដែលមិនអាចសាយភាយ ឬហើរសោត់ (ឧទាហរណ៍ខ្យល់ខ្លាំង) លក្ខខណ្ឌទីវាល (ឧទាហរណ៍ សំណើមដី សុខភាពដំណាំ) ល្អសម្រាប់ផលិតផលពិសេស ពេលប្រើប្រាស់ និងយោងតាមសេចក្តីណែនាំស្លាកផលិតផល។ |
| ថ្នាំកសិកម្មដែលលែងប្រើ (Obsolete Pesticide) | ជាថ្នាំកសិកម្មដែលមិនគួរប្រើប្រាស់តទៅទៀត។ ករណីនេះអាចកើតមានប្រសិនបើផលិតផលនេះ ត្រូវបានដកចេញពីការចុះបញ្ជីក្នុងមូលដ្ឋាន ឬត្រូវបានហាមឃាត់មិនឲ្យប្រើជាអន្តរជាតិ។ ប៉ុន្តែ ជាញឹកញយ ថ្នាំកសិកម្មក្នុងស្តុកថ្នាំប្រែក្លាយជាហួសកាលកំណត់ ដោយសារតែការរក្សាទុកយូរពេក ហើយក្នុងពេលរក្សាទុកនោះ ផលិតផលនិង/ឬសំបកវេចខ្ចប់របស់វា ត្រូវបានខូចខាត។ |

| | |
|---|---|
| ថ្នាំកសិកម្ម (Pesticides) | ជាថ្នាំសម្លាប់សត្វល្អិត ថ្នាំកំចាត់ផ្សិត ថ្នាំសម្លាប់ស្មៅ ថ្នាំសម្លាប់មេរោគ ថ្នាំសម្លាប់កណ្តុរ ថ្នាំកំចាត់សិប្បីសត្វ និងសារធាតុ ឬល្បាយសារធាតុដទៃទៀត ដែលប្រើសម្រាប់ទប់ស្កាត់ កម្ចាត់ ឬគ្រប់គ្រងសត្វចង្រៃ រួមទាំងពូជរុក្ខជាតិ សត្វ ឬអតិសុខុមប្រាណមិនគួរជាទីចង់បានទាំងឡាយ ដែលបង្កខូចខាតក្នុងអំឡុងពេលផលិតកម្ម កែច្នៃ ស្តុកទុក ដឹកជញ្ជូន ឬធ្វើទីផ្សារអាហារ ឬផលិតផលកសិកម្មដទៃទៀត។ |
| ចន្លោះពេលមុនប្រូតកាត់ (Preharvest interval) | ជារយៈពេលចន្លោះដែលត្រូវបានអនុញ្ញាតរវាងការប្រើថ្នាំកសិកម្មចុងក្រោយនៅក្នុងពេលដាំដុះ ទៅដល់ថ្ងៃប្រមូលផលដំណាំដែលបានទទួលការប្រើថ្នាំ ឬស្ថិតក្នុងបរិវេណការប្រើថ្នាំនោះ។ |
| ព្រៃចំបង (Primary forest) | ជាព្រៃដែលមិនធ្លាប់ត្រូវបានធ្វើអាជីវកម្មឈើ ហើយដែលត្រូវបានអភិវឌ្ឍឡើងក្រោយពេលការរំខានផ្នែកធម្មជាតិ និងស្ថិតក្រោមដំណើរការធម្មជាតិ មិនថាព្រៃនោះមានអាយុប៉ុន្មាននោះឡើយ។ "ការរំខានដោយផ្ទាល់ពីមនុស្ស" សំដៅលើការឈូសឆាយព្រៃដោយចេតនា តាមមធ្យោបាយណាមួយ (រួមទាំងការដុតផងដែរ) ដើម្បីគ្រប់គ្រង ឬផ្លាស់ប្តូរទីតាំងនោះសម្រាប់ការប្រើប្រាស់របស់មនុស្ស។ ព្រៃដែលត្រូវបានប្រើប្រាស់តិចតួចដោយជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដែលរស់នៅតាមបែបបទជីវិតប្រពៃណី ទាក់ទងនឹងការអភិរក្ស និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវជីវសាស្រ្តចម្រុះ ក៏ត្រូវបានចាត់ទុកថាជាព្រៃចំបងផងដែរ (ប្រភព ៖http://www.cbd.int/forest/definitions.shtml)។ |
| តំបន់ការពារ (Protected Area) | ជាទីតាំងភូមិសាស្រ្តដែលត្រូវបានកំណត់ ទទួលស្គាល់ បម្រុងទុក និងគ្រប់គ្រងយ៉ាងច្បាស់លាស់ តាមផ្លូវច្បាប់ ឬមធ្យោបាយប្រកបដោយប្រសិទ្ធភាពដទៃទៀត ដើម្បីសម្រេចបានការអភិរក្សរយៈពេលវែងទៅលើធម្មជាតិ ព្រមទាំងសេវាប្រព័ន្ធអេកូឡូស៊ី និងគុណតម្លៃផ្នែកវប្បធម៌។ ឧទាហរណ៍អាចរួមមានដូចជា ឧទ្យានជាតិ តំបន់សត្វព្រៃ តំបន់អភិរក្សសហគមន៍ និងកន្លែងអភិរក្សធម្មជាតិជាដើម។ |
| ប្រព័ន្ធផលិតកម្មពឹងផ្អែកលើទឹកភ្លៀង (Rainfed production system) | ប្រព័ន្ធកសិកម្មដែលមិនមានប្រព័ន្ធធារាសាស្រ្ត ឬបណ្តាញស្រោចស្រព ហើយគ្មានការស្រោចស្រពតាមរយៈការបូមទឹកក្រោមដី និង ទឹកទន្លេ។ |
| តំបន់រ៉ាមសារ (Ramsar Sites) | តំបន់ដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យទាំង ៩ សម្រាប់កំណត់សារៈសំខាន់នៃតំបន់ដីសើមអន្តរជាតិ ក្រោមអនុសញ្ញាស្តីពីដីសើម ឆ្នាំ ១៩៧១ ។ លក្ខណៈវិនិច្ឆ័យទីមួយសំដៅទៅលើទីកន្លែងដែលជាប្រភេទដីសើមដ៏កម្រ ឬប្លែក ហើយនៅសល់លក្ខណៈវិនិច្ឆ័យ ៨ ទៀតសម្រាប់ការអភិរក្សជីវចម្រុះ។ សូមមើលបញ្ជីសារៈសំខាន់នៃដីសើមអន្តរជាតិ (បញ្ជីរ៉ាមសារ) ខាងក្រោម៖ |

| | |
|---|---|
| | http://www.ramsar.org/sites-countries/the-ramsar-sites |
| ពេលវេលាចូលវិញបាន (Re-entry time) | ជាចំនួនថ្ងៃសុវត្ថិភាពអប្បបរមាក្រោយពេលប្រើថ្នាំកសិកម្មរួចហើយ ដែលមានសុវត្ថិភាពដើម្បីចូលទៅក្នុងបរិវេណបាញ់ថ្នាំដោយគ្មានប្រើឧបករណ៍ការពារ។ |
| ការវាយតម្លៃហានីភ័យ (Risk assessment) | ជាដំណើរការជាប្រព័ន្ធ សម្រាប់កំណត់ និងវាយតម្លៃគ្រោះថ្នាក់។ គ្រោះថ្នាក់អាចត្រូវបានកំណត់ឃើញនៅក្នុងបរិស្ថានខាងក្រៅ (ឧ. និន្នាការសេដ្ឋកិច្ច ព្រឹត្តិការណ៍អាកាសធាតុ ការប្រកួតប្រជែង) និងនៅផ្ទៃក្នុង (ឧ. មនុស្ស ដំណើរការ ហេដ្ឋារចនាសម្ព័ន្ធ)។ នៅពេលដែលគ្រោះថ្នាក់ទាំងនេះ រំខានដល់គោលបំណង ឬអាចព្យាករណ៍ថានឹងអាចកើតមាន នោះវានឹងក្លាយជាហានីភ័យ។ |
| ព្រៃបន្ទាប់បន្សំ (Secondary forest) | ជាព្រៃដែលត្រូវបានធ្វើអាជីវកម្មឈើ ហើយបានលូតលាស់ឡើងវិញ មិនថាជាលក្ខណៈធម្មជាតិ ឬជាសិប្បនិម្មិតនោះឡើយ។ ព្រៃប្រភេទនេះ ក៏រួមមាន ព្រៃរិចរិល បានបាត់បង់រចនាសម្ព័ន្ធ ការបំពេញមុខងារ សមាសធាតុពូជ ឬផលិតភាពជាធម្មតារបស់ខ្លួន ដែលពាក់ព័ន្ធនឹងប្រភេទព្រៃធម្មជាតិ ដែលត្រូវគេរំពឹងទុកនៅលើទីតាំងនោះ អាស្រ័យដោយសកម្មភាពមនុស្ស។ (ប្រភព៖ http://www.cbd.int/forest/definitions.shtml)។ |
| គ្រាប់ពូជរក្សាទុកដោយខ្លួនឯង (Self-saved seeds) | គ្រាប់ពូជដែលរក្សាទុកនៅកសិដ្ឋានបន្ទាប់ពីការប្រមូលផល។ ដំណើរការរួមមាន៖ ១) ការសម្អាត និងជ្រើសរើសគ្រាប់ពូជពេញ និងឯកសណ្ឋានបន្ទាប់ពីប្រមូលផល ២) ការសម្ងួតគ្រាប់ពូជឲ្យនៅសំណើម ១២-១៤% និងទី ៣) រក្សាទុកគ្រាប់ពូជក្នុងធុងបិទជិតរហូតដល់ត្រៀមដាំ។ ប្រសិនបើត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវគ្រាប់ពូជរក្សាទុកដោយខ្លួនឯងអាចប្រើក្នុងរយៈពេលរហូតដល់មួយឆ្នាំ។ |
| Short or medium-duration varieties | ពូជអាយុកាលខ្លីមានរយៈពេលចន្លោះពី ៩០ ទៅ ១១០ ថ្ងៃ និងពូជអាយុកាលមធ្យមមានរយៈពេលចន្លោះពី ១២០-១៤០ថ្ងៃ។ ពូជដែលមានរយៈពេលច្រើនជាង ១៤០ ថ្ងៃ ត្រូវបានចាត់ទុកថាជាពូជធ្ងន់។ |
| ទីកន្លែងជាក់លាក់(Site-specific (Field-specific)) | កំណត់ជាក់លាក់ចំពោះតំបន់ដែលបានផ្តល់ (ឧទាហរណ៍ ទីវាល) ។ ឧទាហរណ៍ការកំណត់ពេលវេលាល្អបំផុតសម្រាប់ការដាក់ជីពេលរុក្ខជាតិត្រូវការ បរិមាណសមប និងតាមទីកន្លែងជាក់លាក់ និងជម្រៅឫស។ |
| កសិករខ្នាតតូច (Smallholder) | អ្នកផលិតដែលពឹងផ្អែកជាចម្បងលើកម្លាំងពលកម្មក្នុងគ្រួសារ ឬគ្រួសារ រួមទាំងកម្លាំងពលកម្មផ្លាស់ប្តូរជាមួយសមាជិកដទៃទៀតក្នុងសហ |

| | |
|---|---|
| | គមន៍។ |
| អ្នកបណ្តុះបណ្តាលដែលអនុញ្ញាតដោយ SRP ( SRP Authorized Trainer ) | បុគ្គលដែលបានអនុញ្ញាតដោយ SRP ដើម្បីណែនាំពីការដាំដុះស្រូវប្រកបដោយនិរន្តរភាព រួមមាន វគ្គបណ្តុះបណ្តាលអំពីស្តង់ដារ SRP និងសូចនាករនៃការអនុវត្ត ដែលមានការអនុញ្ញាតពី SRP គម្រោង SRP ដែលបានចុះឈ្មោះ សមាជិក SRP និងអ្នកពាក់ព័ន្ធផ្សេងទៀត។ |
| ផ្ទៃទឹក ( Water body ) | ជាបណ្តុំនៃទឹកក្នុងបរិមាណគួរឲ្យកត់សម្គាល់ ( ជាធម្មជាតិ ឬជាសិប្បនិម្មិត ) រួមមានដូចជា ឧ. បឹង បឹងជាប់សមុទ្រ ស្រះ អាងស្តុកទឹក តំបន់ដីសើម ទន្លេ ស្ទឹង និងប្រឡាយ។ |
| កម្មករ ( Worker ) | មនុស្សដែលបំពេញការងារនៅក្នុងកសិដ្ឋាន ឬសម្រាប់ក្រុមមួយ ឬសមាជិកក្រុមមួយ។ និយមន័យនេះ គ្របដណ្តប់លើកម្មករគ្រប់ប្រភេទទាំងអស់ រួមទាំងកម្មករអចិន្ត្រៃយ៍ កម្មករបណ្តោះអាសន្ន កម្មករចំណាកស្រុក កម្មករឆ្លងកាត់ សមាជិកគ្រួសារ មិនថាជាសមាជិកគ្រួសារដែលបានប្រាក់កម្រៃ ឬមិនបាននោះឡើយ។ |

ភាពខុសគ្នាអាចកើតឡើងរវាងបទដ្ឋាន និងលក្ខខណ្ឌតម្រូវនានាក្រោមច្បាប់ជាតិ ឬតំបន់។ ក្នុងករណីបែបនេះ ដាច់ខាតលក្ខខណ្ឌទាំងពីរនេះត្រូវអនុវត្តលើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

ប្រសិនបើកម្លាំងពលកម្ម ឬសេវាកម្មដែលបានចុះកិច្ចសន្យាត្រូវបានប្រើ ភាគីកិច្ចសន្យា (កសិករខ្នាតតូច អ្នកគ្រប់គ្រងក្រុម ឬកសិដ្ឋានធំ) នៅតែទទួលខុសត្រូវចំពោះការអនុវត្តដោយអ្នកម៉ៅការ។ ឧទាហរណ៍ប្រសិនបើការប្រើប្រាស់ថ្នាំកសិកម្មត្រូវបានចុះកិច្ចសន្យាឱ្យអ្នកផ្តល់សេវាកម្មផ្សេង កសិករ ឬក្រុមកសិករ ត្រូវទទួលខុសត្រូវចំពោះការអនុវត្តន៍របស់អ្នកផ្តលសេវាកម្មដែលពាក់ព័ន្ធនឹងលក្ខខណ្ឌនានា (ឧទាហរណ៍ សម្ភារ និងឧបករណ៍ និងការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់ថ្នាំកសិកម្ម ឧបករណ៍ការពារខ្លួន ការលាងសម្អាត និងផ្លាស់ប្តូរឧបករណ៍ប្រើប្រាស់បម្រាមនៃការប្រើប្រាស់)។

ការកំណត់ត្រាជាលាយលក្ខណ៍អក្សរចាំបាច់ត្រូវមាន កសិករដែលមានកម្រិតវប្បធម៌ទាបអាចស្វែងរកជំនួយពីកូន ៗ របស់ពួកគេ អ្នកគ្រប់គ្រងក្រុម បុគ្គលិកផ្សព្វផ្សាយ ឬអ្នកដទៃទៀត ដើម្បីកត់ត្រា និងរក្សាកំណត់ត្រាជាលាយលក្ខណ៍អក្សរសម្រាប់លក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធ (ឧទាហរណ៍ ប្រតិទិនដំណាំ ការរក្សាទុកកំណត់ត្រា)។

**រូបតំណាង** (Icons) ៖ រូបតំណាងត្រូវបានប្រើ ដើម្បីណែនាំពីកម្រិតនៃការត្រួតពិនិត្យសម្រាប់លក្ខខណ្ឌតម្រូវនីមួយៗដូចដែលបានពិពណ៌នាខាងក្រោម។ ព័ត៌មានលម្អិតបន្ថែម ត្រូវបានផ្តល់ជូននៅក្នុងផ្នែកជានាវ៉ាប់រងរបស់ SRP ។



រូបតំណាងនេះតំណាងឱ្យកសិករទទួលខុសត្រូវចំពោះការតាមដានសកម្មភាព និងរក្សាភស្តុតាងនៃកម្រិតនៃការអនុវត្ត។ ការផ្ទៀងផ្ទាត់កម្រិតនៃការអនុវត្តត្រូវបានធ្វើឡើងនៅកម្រិតកសិដ្ឋាន។



រូបតំណាងនេះបញ្ជាក់ថាជាក្រុមមួយ (ឧទាហរណ៍ សមាគម សហគមន៍ រោងម៉ាស៊ីនកិនស្រូវ អ្នកនាំចេញ តួអង្គក្នុងខ្សែប្រវាក់ផ្គត់ផ្គង់ ដៃគូអង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងាររដ្ឋាភិបាល) ទទួលខុសត្រូវក្នុងការតាមដានសកម្មភាព និងការរក្សាភស្តុតាងកម្រិតនៃការអនុវត្ត។ ការផ្ទៀងផ្ទាត់កម្រិតនៃការអនុវត្តគឺបានធ្វើឡើងនៅកម្រិតក្រុម (ឧទាហរណ៍តាមរយៈអ្នកគ្រប់គ្រងក្រុម ឬអ្នករដ្ឋបាល) ដោយការពិនិត្យបន្ថែមត្រូវបានធ្វើឡើងជាមួយកសិករនៅក្នុងក្រុម។

# លក្ខខណ្ឌតម្រូវនៃបទដ្ឋាន SRP សម្រាប់ការដាំដុះស្រូវប្រកបដោយនិរន្តរភាព ( កំណែ ២.១ )

| ល.រ | ផលប៉ះពាល់ | លក្ខខណ្ឌតម្រូវ | កម្រិតនៃការអនុវត្តន៍តាម | ពិន្ទុ |
|---|---|---|---|---|
| | | **ការគ្រប់គ្រងកសិដ្ឋាន** | | |
| ១ | ផលិតភាពនៃផលចំណេញ | **ប្រតិទិនដាំដុះដំណាំ**<br><br>ប្រតិទិនដាំដុះដំណាំត្រូវបានរៀបចំជាមុនសម្រាប់រដូវដាំដុះនីមួយៗ។ ប្រសិនបើចាំបាច់ វាត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីសម្របទៅនឹងការផ្លាស់ប្តូរនានា ( ឧ.អាកាសធាតុ  ការរងសម្ពាធពីកត្តាចង្រៃ ) ។<br><br>ប្រតិទិនដាំដុះដំណាំបង្ហាញពីកាលបរិច្ឆេទដែលគ្រោងសម្រាប់សកម្មភាពកសិដ្ឋាន និងកាលបរិច្ឆេទជាក់ស្តែងនៃការអនុវត្តសកម្មភាពនានា។ សកម្មភាពទាំងនោះរួមបញ្ចូលចំណុចដូចខាងក្រោម (ប្រសិនបើមាន)៖<br>១) ការកំណត់ពេលវេលាសម្រាប់ដំណើរការសំខាន់ៗ ( ឧ. ការរៀបចំដី ការដាំដុះ ការប្រមូលផល )។<br>២) ការកំណត់ពេលដាក់ជី ( ឧ. គម្រោងបែងចែកការដាក់ជី ) និងសកម្មភាពគ្រប់គ្រងទឹក ( ឧ. ការស្រោចស្រព )។<br>៣) ការកំណត់ពេលវាយតម្លៃកត្តាចង្រៃ និងកម្រិតបំផ្លាញ<br>៤) ការប៉ាន់ប្រមាណកម្លាំងពលកម្ម ឬអ្នកផ្តល់សេវា ( ឧ. គ្រឿងចក្រ )។ | a) ប្រតិទិនដាំដុះដំណាំរួមបញ្ចូលកាលបរិច្ឆេទគ្រោង និងជាក់ស្តែង សម្រាប់គ្រប់សកម្មភាព។<br><br>b) ប្រតិទិនដាំដុះដំណាំមានកាលបរិច្ឆេទគ្រោង និងជាក់ស្តែងសម្រាប់សកម្មភាព ១ និង២ ប៉ុណ្ណោះ។<br><br>c) ប្រតិទិនដាំដុះដំណាំមានកាលបរិច្ឆេទគ្រោងនិងជាក់ស្តែងសម្រាប់សកម្មភាព ១ ប៉ុណ្ណោះ។<br><br>d) មិនមានប្រតិទិនដាំដុះដំណាំ ឬប្រតិទិនដាំដុះដំណាំមិនពេញលេញ ។ | ៣<br><br>២<br><br>១*<br><br>០ |

សញ្ញាផ្កាយ ( * ) សំដៅទៅលើកម្រិតកណ្តាលនៃការអនុវត្ត (Threshold) សម្រាប់លក្ខខណ្ឌតម្រូវនីមួយៗ។ រួមជាមួយពិន្ទុសរុប ៩០% រឺលើសពីនេះ  កម្រិតកណ្តាលនៃការអនុវត្ត (Thresholds) ទាំងនេះត្រូវតែបំពេញ ដើម្បីអះអាងថា" ស្រូវដាំដុះប្រកបដោយនិរន្តរភាព" ។

| លរ | ផលប៉ះពាល់ | លក្ខខណ្ឌតម្រូវ | កម្រិតនៃការអនុវត្តន៍តាម | ពិន្ទុ |
|---|---|---|---|---|
| ២ | ផលិតភាពនៃផលចំណេញ | **ការរក្សាកត់ត្រាទុក**<br>កំណត់ត្រាត្រូវបានរក្សាទុកសម្រាប់រដូវដាំដុះនីមួយៗ។ កំណត់ត្រាទាំងនេះយ៉ាងហោចណាស់ត្រូវឆ្លុះបញ្ចាំងពីកម្រិតទិន្នន័យមូលដ្ឋាន (ងាយប្រមូលដោយកសិករ) និងគួររាប់បញ្ចូលទិន្នន័យនៅកម្រិតមធ្យម (ដែលអាចទាមទារការប្រមូលដោយដៃគូខាងក្រៅ) ។<br><br>**ទិន្នន័យមូលដ្ឋាន** (ប្រសិនបើមាន) ជាឯកត្តាក្នុងស្រុក រួមមាន៖<br>១) ទំហំស្រែ<br>២) ប្រភេទពូជ<br>៣) ចំណាយលើធាតុចូល (ការរៀបចំដី/កំលាំងពលកម្ម/គ្រាប់ពូជ/ថ្នាំកសិកម្ម/ទឹក/សេវាកម្ម)<br>៤) ចំនួនដងដងនៃការស្រោចស្រពកំឡុងពេល និងបន្ទាប់ពីការរៀបចំដី។ | a) មានកំណត់ត្រាទិន្នន័យកម្រិតមធ្យម<br><br>b) មានកំណត់ត្រាទិន្នន័យដែលបញ្ចូលគ្នារវាងទិន្នន័យមូលដ្ឋាន និងទិន្នន័យកម្រិតមធ្យម<br><br>c) មានកំណត់ត្រាទិន្នន័យកម្រិតមូលដ្ឋានប៉ុណ្ណោះ<br><br>d) មិនមានកំណត់ត្រាអ្វីទាំងអស់ | ៣<br><br>២<br><br>១*<br><br>០ |

| ល.រ | ផលប៉ះពាល់ | លក្ខខណ្ឌតម្រូវ | កម្រិតនៃការអនុវត្តន៍តាម | ពិន្ទុ |
|---|---|---|---|---|
| | | ៥) ជីបានប្រើ (ចំនួនដងនៃការប្រើប្រាស់)<br>៦) ថ្នាំកសិកម្មបានប្រើ (ចំនួនដងនៃការប្រើប្រាស់)<br>៧) ទិន្នផលស្រូវ<br>៨) តម្លៃលក់ស្រូវ<br>**ទិន្នន័យកម្រិតមធ្យម (ប្រសិនបើមាន)៖**<br>១) ដូចរាប់រាបខាងលើ ប៉ុន្តែតម្លៃនៃឯកតានីមួយៗ ត្រូវបានបំលែងជាឯកត្តាអន្តរជាតិ។<br>២) ទិន្នន័យប្រសើរច្រើនទៀត ដើម្បីមានលទ្ធភាធ្វើការវិភាគបែបបរិមាណនៃការអនុវត្តនិរន្តរភាព ដូចជា៖<br>- ការគ្រប់គ្រងទឹក (ឧ. បរិមាណទឹកស្រោចស្រព បរិមាណទឹកភ្លៀង ចំនួនថ្ងៃទឹកជំនន់ ចំនួនថ្ងៃ និងរយៈពេលនៃព្រឹត្តិការណ៍រាំងស្ងួត)<br>- ការគ្រប់គ្រងសារជាតុចិញ្ចឹម (ការវិភាគសារជាតុ N និង P ដែលប្រើប្រាស់ បរិមាណជីសរីរាង្គបានប្រើប្រាស់)<br>- ការគ្រប់គ្រងកត្តាចង្រៃ ( ទិន្នន័យការបំផ្លាញពីកត្តាចង្រៃ កំណត់ត្រាផលិតផលសម្រាប់គ្រប់គ្រងកត្តាចង្រៃដែលបានប្រើប្រាស់<br>- ទិន្នន័យផ្សេងៗទៀត។<br>ចំពោះឯកត្តាវាស់វែងនៃកម្រិតទិន្នន័យមធ្យម និងទិន្នន័យមូលដ្ឋានលំអិតជាក់លាក់ផ្សេងទៀតសូមពិនិត្យនៅក្នុងសូចនាករការអនុវត្តរបស់ SRP។ |  | |
| **សកម្មភាពមុនពេលដាំដុះ** | | | | |

| ល.រ | ផលប៉ះពាល់ | លក្ខខណ្ឌតម្រូវ | កម្រិតនៃការអនុវត្តន៍តាម | ពិន្ទុ |
|---|---|---|---|---|
| ៣ | គ្រប់វិស័យទាំងអស់ | **ការបណ្តុះបណ្តាល**<br><br>តម្រូវការការបណ្តុះបណ្តាលកសិករ ព័ត៌មាន និងការគាំទ្រ ត្រូវបានវាយតម្លៃគ្រប់ប្រធានបទក្នុងបទដ្ឋានរបស់ SRP។<br><br>កសិករទទួលវគ្គបណ្តុះបណ្តាលតាមតម្រូវការ  ព័ត៌មាន និងការគាំទ្រ។ អ្នកបណ្តុះបណ្តាលដែលអនុញ្ញាតដោយ SRP ត្រូវបានចាត់ទុកថាជាដៃគូខាងក្រៅដ៏ល្អ ឬ ប្រភពផ្តល់នូវជំនាញច្បាស់លាស់សម្រាប់វគ្គបណ្តុះបណ្តាល SRP ។ SRP ក៏ទទួលស្គាល់ការផ្លាស់ប្តូរព័ត៌មានជាមួយកសិករដទៃ និងជាមួយអង្គការកសិករ ។<br>កសិករបង្ហាញថាខ្លឹមសារពាក់ព័ន្ធគឺបានអនុវត្ត។ | ក្នុងរយៈពេល៥ ឆ្នាំមុន:<br>a) ការបណ្តុះបណ្តាលកសិករ តម្រូវការព័ត៌មាន និងការគាំទ្រត្រូវបានវាយតម្លៃ។ ហើយកសិករទទួលបានការបណ្តុះបណ្តាលពីអ្នកបណ្តុះបណ្តាលដែលអនុវត្តដោយ SRP ហើយកសិករបង្ហាញថាលក្ខខណ្ឌត្រូវទាំងអស់ត្រូវបានអនុវត្ត។ | ៣ |
| | | | b) ការបណ្តុះបណ្តាលកសិករតម្រូវការព័ត៌មាន និងការគាំទ្រត្រូវបានវាយតម្លៃ ហើយកសិករទទួលបានការបណ្តុះបណ្តាល ហើយកសិករបង្ហាញថាលក្ខខណ្ឌត្រូវទាំងអស់ត្រូវបានអនុវត្ត។ | ២ |
| | | | c) ការបណ្តុះបណ្តាលកសិករ តម្រូវការព័ត៌មាន និងការគាំទ្រត្រូវបានវាយតម្លៃ ហើយកសិករទទួលបានការបណ្តុះបណ្តាលតាមតម្រូវការ។ | ១ * |
| | | | d) ការបណ្តុះបណ្តាលកសិករ តម្រូវការព័ត៌មាន និងការគាំទ្រមិនត្រូវបានវាយតម្លៃ។<br> | 0 |

| ល.រ | ផលប៉ះពាល់ | លក្ខខណ្ឌតម្រូវ | កម្រិតនៃការអនុវត្តន៍តាម | ពិន្ទុ |
|---|---|---|---|---|
| ៤ | សុវត្ថិភាពអាហារ | **លោហៈធ្ងន់**<br>អង្ករត្រូវមានសុវត្ថិភាព គ្មានកម្រិតនៃលោហៈធ្ងន់ត្រូវបានរកឃើញក្នុងអង្ករដូចដែលកំណត់ដោយអាជ្ញាធរអន្តរជាតិស្ដីពីសុវត្ថិភាពចំណីអាហារ ឬដោយច្បាប់ ឬបទប្បញ្ញត្តិជាតិ។<br><br>ហានិភ័យនៃការបំពុលដីពីលោហៈធ្ងន់ដូចជា អាសេនិក កាត់ម្ញូម ក្រូម្ញូម បារត និងសំណរត្រូវបានវិភាគ។<br><br>បើមានការបំពុលដីដោយលោហៈធ្ងន់៖<br>១) ការវិភាគនៃកម្រិតក្រុមដីត្រូវបានធ្វើនៅតំបន់ដែលមានការបំផុតយ៉ាងតិចរាល់៥ឆ្នាំម្ដង។<br>២) បច្ចេកទេសនានាក្នុងការកែលំអរដីត្រូវបានអនុវត្ត។ | a) មានឯកសារភស្តុតាង (មិនលើសពី៥ឆ្នាំ) ដែលបានបញ្ជាក់ថាអង្ករមានសុវត្ថិភាពគ្មានលោហៈធ្ងន់ | ៣ |
| | | | b) មានឯកសារភស្តុតាង (មិនលើសពី៥ឆ្នាំ ដោយការវិភាគតាមក្រុមដី ឬប្រភពដែលអាចទុកចិត្តបាន) ដែលបង្ហាញថាកម្រិតលោហៈធ្ងន់ក្នុងដីរបស់ក្រុមដីឬតំបន់នោះមិនមានលើសពីកម្រិតដើម។ | ៣ |
| | | | c) ការវាយតម្លៃហានីភ័យតាមក្រុម (មិនលើសពី៥ឆ្នាំ) បង្ហាញថាមិនមានហានីភ័យពីការបំពុលនៃលោហៈធ្ងន់ទេ (សូមមើលក្នុងឧបសម្ព័ន្ធ A តារាងវាយតម្លៃហានិភ័យ) | ២ * |
| | | | d) ករណីមានហានិភ័យ ការវិភាគតាមក្រុមដីត្រូវធ្វើយ៉ាងតិចរាល់៥ឆ្នាំម្ដង ហើយប្រសិនបើមានការបំផុតដីដោយលោហៈធ្ងន់បច្ចេកទេសកែលំអរដីត្រូវបានអនុវត្តមិនមានដូចអ្វីដែលបានរៀបរាប់ខាងលើ។ | ១ |
| | | | e) គ្មានការអនុវត្តដូចខាងលើ | 0 |

| ល.រ | ផលប៉ះពាល់ | លក្ខខណ្ឌតម្រូវ | កម្រិតនៃការអនុវត្តតាម | ពិន្ទុ |
|---|---|---|---|---|
| ៥ | ផលិតភាពនៃផលចំណេញប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក | **ជាតិប្រៃក្នុងដី**<br>ហានិភ័យជាតិប្រៃក្នុងដីត្រូវបានវិភាគ។ ជាតិប្រៃក្នុងដីត្រូវបានគ្រប់គ្រងឱ្យនៅកម្រិតទទួលយកបាន (មិនលើសពី ៣ dS/cm ចំពោះដី ឬ ៥ ក្រាម/លីត្រចំពោះទឹក ហើយគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នៅពេលកម្រិតជាតិប្រៃកើនឡើងខ្ពស់។<br><br>ពេលមានហានិភ័យជាតិប្រៃក្នុងដី វិធីសាស្ត្រកាត់បន្ថយ ឬបន្សុំរួមមានដូចខាងក្រោម៖<br>-ការប្រើប្រាស់ពូជធន់នឹងជាតិប្រៃ<br>-ការតាមដានជាតិប្រៃក្នុងទឹកស្រែ<br>-ការគ្រប់គ្រងជាតិប្រៃ តាមរយៈការរក្សាសំពាធទឹកនៅក្នុងស្រែ<br>- ការគ្រប់គ្រងលំហូរទឹកចូល/ចេញទាំងបរិមាណទឹក និងការកំណត់ពេលវេលាដើម្បីបន្ថយជាតិប្រៃ<br>- ដំបូន្មានពីអ្នកជំនាញ និងសកម្មភាពដែលធ្វើឡើងបន្ទាប់ពីនោះមក | a) មានឯកសារភស្តុតាង មិនយូរជាង ៣ ឆ្នាំ បញ្ជាក់ថា៖<br>-មិនមានហានីភ័យនៃជាតិប្រៃក្នុងដីនៅក្នុងក្រុមដី /តំបន់ ឬ<br>-ជាតិប្រៃក្នុងដីនៃក្រុមដី ឬតំបន់មានក្នុងកម្រិតទទួលយកបាន (កបង្ហាញថាជាតិប្រៃក្នុងដីគឺស្ថិតក្នុងកម្រិតអាចទទួលយកបាន (មិនលើសពី ៣ dS/cm ចំពោះដី ឬ ៥ ក្រាម/លីត្រចំពោះទឹក) ។ | ៣ |
| | | | b) មាន (ហានីភ័យ) នៃជាតិប្រៃ ហើយវិធានការកាត់បន្ថយ/បន្សុំត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។ | ២ |
| | | | c) មាន (ហានីភ័យ) នៃជាតិប្រៃ ហើយវិធានការកាត់បន្ថយ/បន្សុំត្រូវអនុវត្ត។ | ១* |
| | | | d) មិនមែនដូចអ្វើបានលើកឡើងខាងលើ។<br> | 0 |

| | | | | |
|---|---|---|---|---|
| ៦ | ជីវចម្រុះ<br>ការបំភាយឧស្ម័នផ្ទះកញ្ចក់ | **ការផ្លាស់ប្តូរដី និងជីវចម្រុះ**<br>ការធ្វើស្រែក្រោយឆ្នាំ ២០០៩ មិនបានបណ្តាលឱ្យការផ្លាស់ប្តូរ (ស្មើ) ក្នុងតំបន់ការពារ  តំបន់ជីវៈចម្រុះសំខាន់ តំបន់រ៉ាមសារ (តំបន់ដីសើម) ព្រៃដំបូង ព្រៃបន្ទាប់បន្សំ (ព្រៃដើម) ឬប្រព័ន្ធអេកូឡូស៊ីធម្មជាតិផ្សេងទៀត និងប្រភេទដីដូចជាវាលស្មៅ។ | a) គ្មានការធ្វើកសិកម្មក្នុងតំបន់បានរៀបរាប់ក្រោយឆ្នាំ២០០៩ ហើយការធ្វើកសិកម្មរក្សា ឬ/និងធ្វើឱ្យប្រសើរឡើងនូវជីវចម្រុះក្នុងតំបន់ និងសេវាប្រអេកូឡូស៊ី  | ៣ |
| **លេ.រ** | **ផលប៉ះពាល់** | **លក្ខខណ្ឌតម្រូវ** | **កម្រិតនៃការអនុវត្តតាម** | **ពិន្ទុ** |
| | | នៅវាលស្រែ កសិកត្រូវរក្សា និងធ្វើឱ្យប្រសើរឡើងនូវធាតុនៃជីវចម្រុះក្នុងតំបន់ដូចជា៖<br>- ជម្រកសម្រាប់ជីវចម្រុះផ្សេងៗក្នុងវាលស្រែ<br>- មានទុកជាយស្រែ<br>- តំបន់មិនដាំដំណាំ<br>- ប្រភេទរុក្ខជាតិជាជម្រកមានប្រយោជន៍សម្រាប់សត្រូវធម្មជាតិ<br>- ដើមឈើ (ដាំឡើងវិញប្រសិនបើប្រមូលផលរួច)<br>អនុវត្តកសិកម្មរក្សា និងធ្វើឱ្យប្រសើរឡើងនូវសេវាប្រព័ន្ធអេកូឡូស៊ី។ | b) គ្មានការធ្វើកសិកម្មនៅតំបន់បានរៀបរាប់ក្រោយឆ្នាំ២០០៩ ហើយការធ្វើកសិកម្មរក្សា ឬ/និងធ្វើឱ្យប្រសើរឡើងនូវជីវចម្រុះក្នុងតំបន់ | ២ |
| | | | c) គ្មានការធ្វើកសិកម្មនៅតំបន់បានរៀបរាប់ក្រោយឆ្នាំ២០០៩ | ១* |
| | | | d) មានការធ្វើកសិកម្មនៅក្នុងតំបន់ដែលបានរៀបរាប់ក្រោយឆ្នាំ២០០៩។  | ០ |
| ៧ | ជីវៈចម្រុះ | **ប្រភេទដែលមានលក្ខណៈរាតត្បាត**<br><br>គ្មានប្រភេទពូជដែលមានលក្ខណៈរាតត្បាត (ឧ. កំប្លោក ឬ ខ្យងមាស) ត្រូវ | a) គ្មានប្រភេទពូជដែលមានលក្ខណៈរាតត្បាតត្រូវបាននាំមកឲ្យមានឡើយ។ | ៣* |

| | | | | |
|---|---|---|---|---|
| | | បាននាំមកឱ្យមានឡើយ ដោយកសិករ ឬក្រុមកសិករចាប់តាំងពីឆ្នាំ២០០៩។<br><br>នៅពេលមានវត្តមានប្រភេទពូជរាតត្បាត វិធានការគ្រប់គ្រងយ៉ាងមានប្រសិទ្ធ ត្រូវបានអនុវត្តប្រឆាំងនឹងប្រភេទពូជរាតត្បាតទាំងនោះ ដើម្បីការពារប្រភេទពូជក្នុងតំបន់។ | b) ប្រភេទពូជដែលមានលក្ខណៈរាតត្បាតត្រូវបាននាំមកតាំងពីឆ្នាំ២០០៩ ហើយត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព។ | ១ |
| | | | c) ប្រភេទពូជដែលមានលក្ខណៈរាតត្បាតត្រូវបាននាំមកតាំងពីឆ្នាំ២០០៩ ហើយមិនត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។  | ០ |
| ៨ | ផលិតភាពនៃផលចំណេញ<br><br>ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក<br><br>ជីវចម្រុះ | **ការពង្រាបដី**<br><br>ការណែនាំ: ធ្វើការកំណត់ប្រព័ន្ធដែលអនុវត្តលើដីសំខាន់សម្រាប់ដាំដុះ។ ការឆ្លើយតបសម្រាប់ប្រព័ន្ធ៖<br>-ដីទំនាប ឬ ទីជម្រាលរាបស្មើ<br>-ដីជម្រាលមិនរាបស្មើ<br>-ដីស្ងួត (គ្មានប្រព័ន្ធស្រោចស្រព)<br><br>**ស្រូវបានដាំដុះលើដីទំនាប ឬដីជម្រាលរាបស្មើ៖**<br><br>-ប្រសិនបើការពង្រាបដីដោយឡាស៊ែត្រូវបានប្រើ ដី ឬជម្រាលរាបស្មើមានកម្រិតរហូតដល់ ០,១% នៃជម្រាលស្រែ<br>-ប្រសិនបើការពង្រាបដីដោយឡាស៊ែមិនត្រូវបានប្រើ ហើយការសង្កេតដោយភ្នែកបញ្ជាក់ថា វាលស្រែមិនមានកន្លែងខ្ពស់ទាបនៅពេលដាក់ទឹក ហើយកំពស់ដំណាំមានឯកសណ្ឋានភាព (គ្មានខ្ពស់ទាប)។ | ចំពោះដីរាបស្មើ ឬដីទួលរាបស្មើ៖<br><br>a) ដីត្រូវបានពង្រាបនៅកម្រិត ០,១% នៃជម្រាលស្រែ | ៣ |
| | | | b) ដីត្រូវបានពង្រាបឱ្យស្មើ | ២* |
| | | | c) ដីមិនត្រូវបានពង្រាបឱ្យស្មើ | ០ |
| | | | ចំពោះដីជម្រាលមិនរាបស្មើ៖<br>a) ការអនុវត្តការអភិរក្សដីតាមបែបរូបសាស្ត្រ និងក្សេត្រសាស្ត្រត្រូវបានអនុវត្ត | ៣ |

| | | | | |
|---|---|---|---|---|
| | | **ស្រូវបានដាំដុះនៅលើដីជម្រាលមិនរាបស្មើ៖**<br>-ការអនុវត្តការអភិរក្សដីតាមបែបរូបសាស្ត្រ (កសិកម្មវណ្ឌវង្សនៅទីជម្រាល ធ្វើរបាំងទប់ការហូរច្រោះដី<br>-ការអនុវត្តការអភិរក្សដីតាមបែបក្សេត្រសាស្ត្រត្រូវបានប្រើ (ឧ.ការដាំដំណាំគម្របដីមិនមានលក្ខណៈរាតត្បាត, ការគ្របដី)។ | b) ការអនុវត្តការអភិរក្សដីតាមបែបរូបសាស្ត្រតែប៉ុណ្ណោះ<br>c) គ្មានការអនុវត្តការអភិរក្សដីទេ។<br>ដីស្ងួត (គ្មានប្រព័ន្ធស្រោចស្រព)៖<br>a) មិនតម្រូវឱ្យមានការពង្រាបដី ប៉ុន្តែករណីដីជម្រាល ទាំងការអនុវត្តការអភិរក្សដីតាមបែបរូបសាស្ត្រ (ឧ. ការដាំដុះវណ្ឌវង់) ឬតាមបែបក្សេត្រសាស្ត្រ (ឧ.គម្របដី) ត្រូវបានអនុវត្ត។<br> | ២*<br>០<br>៣ |
| ៩ | ផលិតភាពនៃផលចំណេញ | **គ្រាប់ពូជស្រូវសុទ្ធមានគុណភាព**<br>គ្រាប់ពូជស្រូវសុទ្ធមានគុណភាពគ្មានគ្រាប់ស្មៅ សត្វល្អិត និងជំងឺផ្សេងៗ។<br>គ្រាប់ពូជដែលបានបញ្ជាក់ ហើយអនុលោមតាមច្បាប់/បទបញ្ញត្តិជាតិ ឬបទបញ្ញតិទីផ្សារគោលដៅ។<br>គ្រាប់ពូជដែលត្រួតពិនិត្យគុណភាព (គ្មានការបញ្ជាក់) ត្រូវតែគោរពលក្ខខណ្ឌដូចជា ភាពសុទ្ធនៃគ្រាប់ពូជ គ្មានគ្រាប់ស្មៅ ការធ្វើតេស្តដំណុះគ្រាប់ ទុកដាក់មានសុវត្ថិភាព គ្រប់គ្រងផ្សិត ជាដើម។<br>គ្រាប់ពូជដែលរក្សាទុកដោយខ្លួនឯងជាមួយនឹងការត្រួតពិនិត្យគុណភាពត្រូវតែ | a) កសិករប្រើគ្រាប់ពូជវិញ្ញាបនបត្រសមស្រប សម្រាប់លក្ខខណ្ឌមូលដ្ឋាននិងត្រូវលក្ខណៈវិនិច្ឆ័យសម្រាប់គ្រាប់ពូជវិញ្ញាបនបត្រ។<br>b) កសិករប្រើគ្រាប់ពូជដែលត្រួតពិនិត្យគុណភាពសមស្របសម្រាប់លក្ខខណ្ឌមូលដ្ឋាន និង បំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់គ្រាប់ពូជដែលមានគុណភាពគ្រប់គ្រង<br>c) កសិករប្រើគ្រាប់ពូជរក្សាទុកដោយខ្លួនឯងដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់គ្រាប់ពូជ | ៣<br>៣<br>២* |

| | | | | |
|---|---|---|---|---|
| | | បំពេញតាមលក្ខណៈវិនិច្ឆ័យរួមទាំងការស្តុកមានសុវត្ថិភាព ការកាត់ពូជលាយ (ដកចេញប្រភេទពូជពូជផ្សេង) នៅទីវាលមុនពេលប្រមូលផល។ ការប្រើប្រាស់គ្រាប់ពូជរក្សាទុកដោយខ្លួនឯងមិនត្រូវលើសពី៣ដងនៃវដ្តដំណាំ។ | រក្សាទុកដោយខ្លួនឯង និងមានការត្រួតពិនិត្យគុណភាពសម្រាប់រយៈពេលមិនលើសពី៣ដងនៃវដ្តដំណាំដុះ។<br><br>d) កសិករប្រើគ្រាប់ពូជ៖<br>- គ្រាប់ពូជគ្មានការបញ្ជាក់<br>- គ្រាប់ពូជគ្មានការត្រួតពិនិត្យគុណភាព<br>- គ្រាប់ពូជរក្សាខ្លួនឯងដោយគ្មានការត្រួតពិនិត្យគុណភាព<br>- គ្រាប់ពូជរក្សាខ្លួនឯងលើសពី៣ដងនៃវដ្តដាំដុះ។<br> | ០ |
| **ការប្រើប្រាស់ទឹក** | | | | |
| ១០ | ផលិតភាពនៃផលចំណេញ<br><br>ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក<br><br>ការបំភាយឧស្ម័យ | **ការគ្រប់គ្រងទឹក**<br><br>សេចក្តីណែនាំ៖ កំណត់ប្រព័ន្ធផលិតកម្មក្នុងតំបន់ដែលបានអនុវត្តលើដីភាគច្រើនដែលកំពុងដាំដុះ។<br><br>ឆ្លើយតបចំពោះតែលក្ខខណ្ឌតម្រូវសម្រាប់ប្រព័ន្ធខាងក្រោមនេះ៖<br>• ប្រព័ន្ធផលិតកម្មពឹងផ្អែកលើទឹកភ្លៀង (១០.១)<br>• ប្រព័ន្ធផលិតកម្មដោយការស្រោចស្រព - តំបន់លិចទឹក (១០.២) | | |

| | | | | |
|---|---|---|---|---|
| | ផ្ទះកញ្ចក់ | • ប្រព័ន្ធផលិតកម្មដោយការស្រោចស្រព - តំបន់មិនលិចទឹក (១០.៣) | | |
| ១០.១ | | ***ប្រព័ន្ធផលិតកម្មពឹងផ្អែកលើទឹកភ្លៀង***<br><br>វិធានការត្រូវបានធ្វើឡើង ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការប្រើប្រាស់ទឹករួមមាន៖<br><br>1. ធ្វើការដាំដុះដំណាំឱ្យបានទាន់ពេលវេលា និងសមស្របតាមអាកាសធាតុក្នុងតំបន់។<br>2. ការដាំដោយគ្រាប់ផ្ទាល់ ឬការរាស់បំបែកដីជាភក់ ម៉ត់ល្អ និងការធ្វើភ្លឺស្រែឱ្យរឹងមាំ។<br>3. ការប្រើប្រាស់ពូជសមស្របសម្រាប់អាកាសធាតុក្នុងតំបន់ (ឧ. ពូជអាយុកាលខ្លី ឬមធ្យម) ។<br>4. ការធ្វើការប្រមូលផលទឹកភ្លៀងនៅនឹងកន្លែង និងស្តុកទុកសម្រាប់ស្រោចស្រពបន្ថែម។ | a) កសិករអនុវត្តតាមវិធានការទាំងបួននោះ។<br><br>b) កសិករអនុវត្តតាមវិធានការ ១ ២ និង ៣<br><br>c) កសិករអនុវត្តតាមវិធានការ ១ និង ២ ប៉ុណ្ណោះ ។<br><br>d) មិនបានអនុវត្តវិធានការទាំង ៤ ។<br><br> | ៣<br><br>២<br><br>១*<br><br>០ |
| ១០.២ | | ***ប្រព័ន្ធផលិតកម្មដោយការស្រោចស្រព- តំបន់លិចទឹកជំនន់***<br><br>វិធានការត្រូវបានធ្វើឡើងដើម្បីបង្កើនការប្រើប្រាស់ទឹកប្រសិទ្ធភាពរួមមាន៖<br><br>1. ធ្វើការដាំដុះដំណាំឱ្យបានទាន់ពេលវេលា ដើម្បីចៀសវាងការលិចទឹកក្នុងកំឡុងពេលអាចកើតមានទឹកជំនន់ ។<br>2. ប្រសិនបើអាច ត្រូវបង្ហូរទឹកចេញទុកឱ្យស្ងួតបានយ៉ាងហោចណាស់មួយដង (ឧ. ការបង្ហូរទឹកនៅពាក់កណ្តាលនៃរយៈពេល ៧ ថ្ងៃម្តង ។<br>3. ធ្វើការពង្រាបដីឱ្យស្មើសម្រាប់លក្ខខណ្ឌបង្ហូរទឹកចេញ។<br>4. ការប្រើប្រាស់ពូជដែលធន់នឹងទឹកជំនន់។ | a) កសិករអនុវត្តតាមវិធានការ ១ និងវិធានការបន្ថែមចំនួន២ ផ្សេងទៀត។<br><br>b) កសិករអនុវត្តតាមវិធានការ ១ និងវិធានការបន្ថែមចំនួន១ ផ្សេងទៀត។<br><br>c) កសិករអនុវត្តតាមវិធានការ ១ ប៉ុណ្ណោះ។<br><br>d) កសិករមិនបានអនុវត្តតាមវិធានការទាំងបួននោះ។<br><br> | ៣<br><br>២<br><br>១*<br><br>០ |

| | | | | |
|---|---|---|---|---|
| | | | | |
| ១០.៣ | | *ប្រព័ន្ធផលិតដោយការស្រោចស្រព - តំបន់មិនលិចទឹកជំនន់*<br>វិធានការត្រូវបានធ្វើឡើង ដើម្បីធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធភាពរួមមាន៖<br>1. ការភ្ជួររាស់មួយដងមុនពេលទឹកលិចប្រសិនបើដីបែកក្រហែង។<br>2. ធ្វើការពង្រាបដី និងមានភ្លឺស្រែរឹងមាំ។<br>3. ការដាំគ្រាប់ស្ងួត ឬស្ទូង បន្ទាប់ពីដីសើម, បំបែកដីឱ្យបានម៉ត់ល្អ (ភក់) និងភ្ជួររាស់ បន្ទាប់ពីរយៈពេលមួយសប្តាហ៍។<br>4. ប្រើប្រាស់បច្ចេកទេស សើមនិងស្ងួត (AWD)។<br>5. ការប្រើប្រាស់ពូជអាយុកាលខ្លី ឬ មធ្យម ដែលមានសក្តានុពលទិន្នផលប្រហែលពូជអាយុកាលវែង។<br>6. បញ្ឈប់ការស្រោចស្រពហោចណាស់ ១០-១៥ថ្ងៃមុនពេលប្រមូលផល។ | a) កសិករអនុវត្តតាមវិធានការ ទាំង ៦នោះ។<br>b) កសិករអនុវត្តតាមវិធានការ ២, ៣ និង ៦ ប៉ុណ្ណោះ ។<br>c) កសិករអនុវត្តតាមវិធានការ ២ និង ៤ ប៉ុណ្ណោះ ។<br>d) កសិករមិនបានអនុវត្តតាមវិធានការទាំងនោះ។<br> | ៣<br>២<br>១ *<br>0 |
| ១១ | ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក | **ប្រព័ន្ធស្រោចស្រពកម្រិតសហគមន៍**<br>ប្រព័ន្ធធារាសាស្ត្រដែលស្ថិតនៅក្រោមបញ្ជារបស់កសិករ ឬ ក្រុមកសិករ (ផ្គត់ផ្គង់ដោយទឹកលើដី ឬទឹកក្រោមដី) អនុលោមតាមលក្ខណៈវិនិច្ឆ័យខាងក្រោម:<br>1. ផ្ទៃដីស្រោចស្រពបានមានប្រឡាយគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ និងបង្ហូរទឹកចេញ។<br>2. មិនមានទឹកលេចជ្រាបចេញពីទំនប់ទឹកទេ។<br>3. ទ្វារបង្ហូរ (ប្រសិនបើមាន) មានដំណើរការល្អ។ | a) កសិករផលិតស្រូវដោយពឹងផ្អែកលើទឹកភ្លៀង។<br>b) អនុវត្តតាមលក្ខខណ្ឌដែលមានរៀបរាប់ទាំងបួន<br>c) អនុវត្តតាមលក្ខខណ្ឌចំនួនបីនៃលក្ខខណ្ឌដែលបានរៀបរាប់<br>d) អនុវត្តតាមលក្ខខណ្ឌចំនួនពីរនៃលក្ខខណ្ឌដែលបានរៀបរាប់ | គ្មាន<br>៣<br>២ *<br>១ |

| | | | | |
|---|---|---|---|---|
| | | 4. មានការចូលរួមពីភាគីពាក់ព័ន្ធក្នុងការសម្រេចចិត្តលើការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ។ | e) មិនបានអនុវត្តទាំងអស់   | 0 |
| ១២ | ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក<br>សុវត្ថិភាពអាហារ | **គុណភាពទឹកបញ្ចូលស្រែ**<br>ទឹកបញ្ចូលស្រែបានមកពីប្រភពទឹកស្អាតដែលគ្មានការលាយឡំជាមួយនឹងសារធាតុជីវសាស្ត្រ ជាតិប្រៃ និងលោហៈធ្ងន់។<br>ករណីមានវត្តមាននៃ (ហានិភ័យនៃ) កខ្វក់ទឹកបច្ចេកទេសកែលម្អត្រូវបានអនុវត្ត ជាឧទាហរណ៍ការដំឡើងប្រព័ន្ធចម្រោះទឹក ឬការជ្រើសរើសពូជធន់មកជំនួសប្រសិនបើមាន។ | a) កសិករផលិតស្រូវដោយពឹងផ្អែកលើទឹកភ្លៀង (គ្មានប្រព័ន្ធធារាសាស្ត្រ) ។ | គ្មាន |
| | | | b) មានឯកសារភស្តុតាងមិនលើសពី ៣ ឆ្នាំ (តាមវិធីសាស្ត្រណាមួយក្នុងកំណត់សម្គាល់ ១៦) ថាទឹកហូរចូលស្រែគឺទទួលបានពីប្រភពស្អាត។ | ៣ |
| | | | c) ដូចគ្នានឹងចំនុច b ដែរ ប៉ុន្តែឯកសារភស្តុតាងបញ្ជាក់ចាស់ជាង ៣ ឆ្នាំ។ | ២ |
| | | | d) ក្នុងករណី (ហានិភ័យនៃ) ទឹកកខ្វក់ វិធានការកាត់បន្ថយ ត្រូវបានយកមកអនុវត្ត ដើម្បីបន្ថយផលប៉ះពាល់ដែលអាចកើតមានដោយសារទឹកកខ្វក់។ | ១* |
| | | | e) គ្មានការអនុវតដូចខាងលើ។  | 0 |

| | | | | |
|---|---|---|---|---|
| ១៣ | ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក | **ការទាញយកទឹកក្រោមដី**<br><br>ការទាញយកទឹកក្រោមដីគឺស្របច្បាប់ និងមាននិរន្តរភាព។<br><br>ការទាញយកទឹកដោយនិរន្តរភាពជៀសវាងការបំផ្លាញដល់ធនធានទឹកហួសពីសមត្ថភាពស្តារឡើងវិញរបស់ប្រភពទឹក និងរក្សាតុល្យភាពភាពនៃការប្រើប្រាស់វា។ | a) កសិករផលិតស្រូវដោយពឹងផ្អែកលើទឹកភ្លៀង (គ្មានប្រព័ន្ធធារាសាស្ត្រ) ។ | គ្មាន |
| | | | b) ការទាញយកទឹកអនុលោមតាមគោលនយោបាយផ្តល់អាជ្ញាប័ណ្ណការទាញយកទឹកប្រកបដោយនិរន្តរភាព។ | ៣ |
| | | | c) ក្នុងរយៈពេល ៣ ឆ្នាំកន្លងមក កសិករបានអនុវត្តតាមការណែនាំរបស់អ្នកជំនាញលើការប្រើប្រាស់ទឹកក្រោមដីប្រកបដោយនិរន្តរភាព។ | ២ * |
| | | | d) មានការចូលរួមយ៉ាងសកម្មនៅក្នុងគម្រោងនៃការគ្រប់គ្រងទីជម្រាល និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទឹកក្រោមដីជាលក្ខណៈសហគមន៍។ | ១ |
| | | | e) គ្មានការអនុវត្តដូចខាងលើ  | 0 |
| ១៤ | ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក | **ការបង្ហូរទឹកចេញ** | a) កសិករផលិតស្រូវដោយពឹងផ្អែកលើទឹកភ្លៀង (គ្មានប្រព័ន្ធធារាសាស្ត្រ) ។ | គ្មាន |

| | | | | |
|---|---|---|---|---|
| | ជីវចម្រុះ | ការបង្ហូរទឹកចេញក្រោយពេលមានការប្រើសារជាតុគីមីកសិកម្មត្រូវពន្យាពេលឱ្យគ្រប់គ្រាន់ ដើម្បីជៀសវាងការធ្វើឲ្យមានការប៉ះពាល់ដោយសារជាតុគីមីដែលហូរចេញ ហើយផ្អែកលើព័ត៌មានណែនាំពីផលិតផល ។ ការហូរចេញនៃសារជាតុគីមីកសិកម្មអាចជះឥទ្ធិពលអវិជ្ជមានដល់ជីវចម្រុះនៅតំបន់ជុំវិញ និងខ្សែទឹក។ | b) គ្មានការបង្ហូរទឹកខាងលើចេញ ដោយសារមានការអនុវត្តល្អនៅនឹងទឹកន្លែង។<br><br>c) មានការបង្ហូរទឹកខាងលើចេញ ប៉ុន្តែគ្មានការប្រើប្រាស់សារជាតុគីមីកសិកម្ម។<br><br>d) ការបង្ហូរទឹកចេញត្រូវបានពន្យាពេលក្រោយពេលដាក់សារជាតុគីមីកសិកម្មនៅផ្នែកខាងលើយ៉ាងហោចណាស់៤ថ្ងៃសម្រាប់ជី និង១៤ថ្ងៃសម្រាប់ថ្នាំកសិកម្ម ឬផ្អែកលើលើសំបកផលិតផល។<br><br>e) ការបង្ហូរទឹកចេញត្រូវបានពន្យាពេលក្រោយពេលមានការដាក់សារជាតុគីមីកសិកម្មនៅផ្នែកខាងលើ ប៉ុន្តែមានរយៈពេលខ្លីជាងនេះ ដោយសារតម្រូវការមិនអាចរំពឹងទុកបាន ដើម្បីការពារដំណាំ។<br><br>f) គ្មានការអនុវត្តដូចខាងលើ  | ៣<br><br>៣<br><br>២*<br><br>១<br><br>0 |
| **ការគ្រប់គ្រងសារធាតុចិញ្ចឹម** | | | | |
| ១៥ | ផលិតភាពនៃផល | **ការគ្រប់គ្រងសារជាតុចិញ្ចឹម** | a) កសិករអនុវត្តតាមវិធានការទាំងបីដែលបានរៀបរាប់។ | ៦ |

| | | | | |
|---|---|---|---|---|
| | ចំណោញ<br>ប្រសិទ្ធភាពនៃការប្រើប្រាស់សារជាតុចិញ្ចឹមដីរចម្រុះ<br>ការបំភាយឧស្ម័នផ្ទះកញ្ចក់ | ការគ្រប់គ្រងសារជាតុចិញ្ចឹមប្រកបដោយប្រសិទ្ធភាពបានអនុវត្ត និងកត់ត្រា<br>វិធានការសម្រាប់គ្រប់គ្រងសារជាតុចិញ្ចឹមដោយប្រសិទ្ធភាពរួមមាន៖<br>1. កំណត់ពេលវេលាប្រើប្រាស់ដី (សរីរាង្គ(ធម្មជាតិ) ឬ/និងជីគីមី (N P ឬ/និង K) ទៅតាមតម្រូវការរបស់ដំណាំ តាមអនុសាសន៍នៃការប្រើប្រាស់ជីក្នុងតំបន់ ឬការណែនាំរបស់ផលិតផល (ប្រសិនបើមាន)។<br>2. បរិមាណជី (សរីរាង្គ/គីមី (N, P, K) ដែលប្រើគឺតាមជីជាតិដី និងទិន្នផលដែលចង់បាន, តាមអនុសាសន៍នៃការប្រើប្រាស់ជី និងការណែនាំរបស់ផលិតផល (ប្រសិនបើមាន)។<br>3. ការធ្វើឱ្យប្រសើរឡើងនូវជីជាតិដីតាមបែបប្រព័ន្ធធម្មជាតិ (ឧ.ការដាំដំណាំបង្វិល, ការដាំដំណាំឆ្លាស់ និងការដាំដំណាំគម្របដី) ត្រូវបានអនុវត្ត។ | b) កសិករអនុវត្តតាម ២វិធានការក្នុងចំណោម៣វិធានការដែលបានរៀបរាប់។ | ៤ * |
| | | | c) កសិករអនុវត្តតាម ១វិធានការក្នុងចំណោម៣វិធានការដែលបានរៀបរាប់។ | ២ |
| | | | d) កសិករមិនអនុវត្តតាមចំណុចណាមួយដែលបានរៀបរាប់ | ០ |
| ១៦ | ផលិតភាពនៃផលចំណោញ<br>ប្រសិទ្ធភាពនៃការប្រើប្រាស់សារជាតុចិញ្ចឹម<br>ការបំភាយឧស្ម័នផ្ទះកញ្ចក់ | **ជម្រើសជីសរីរាង្គ**<br>សារជាតុសរីរាង្គ (លាមកសត្វ ជីស្រស់ គម្របដី ចំបើង) ត្រូវបានប្រើប្រាស់ជាជីប្រសិនបើលក្ខខណ្ឌអំណោយផល។<br>លក្ខខណ្ឌអំណោយផលមានដូចជា៖<br>1. វាអាចប្រើប្រាស់នៅលើស្រែមិនលិចទឹកក្នុងទម្រង់ជាជីកំប៉ុស្តិ៍ ឬរលួយ<br>2. ទុកពេលវេលាគ្រប់គ្រាន់សម្រាប់វារលួយជាកំប៉ុស្តិ៍មុនទឹកជំនន់។<br>3. វាមានបរិមាណគ្រប់គ្រាន់ និងរកបានក្នុងមូលដ្ឋាន (ចំងាយមិនលើសពី 50 គីឡូម៉ែត្រ) ។ | a) កសិករប្រើប្រាស់សម្ភារសរីរាង្គ ជាជីទៅតាមលក្ខខណ្ឌទាំងបីដែលបានចែង។ | ៣ |
| | | | b) កសិករប្រើប្រាស់សម្ភារសរីរាង្គជាជីទៅតាមលក្ខខណ្ឌ ១ និង ២ ប៉ុណ្ណោះ។ | ៣ |
| | | | c) កសិករមិនប្រើសម្ភារសរីរាង្គជាជីទេ ពីព្រោះវាមិនត្រូវនឹងលក្ខខណ្ឌមួយ រឺច្រើនដែលបានរៀបរាប់។ | ២ * |
| | | | d) កសិករមិនប្រើសម្ភារសរីរាងជាជីទេ ទោះបីជាកសិករយល់ដឹងពីលក្ខខណ្ឌទាំងនោះ និងត្រូវនឹងលក្ខខណ្ឌទាំងនោះក៏ដោយ។ | ១ |

| | | | | |
|---|---|---|---|---|
| | | | e) កសិករគួរលុបសម្ភារសរីរាង្គចូលទៅក្នុងដីដែលលិចទឹក។<br> | ០ |
| ១៧ | ផលិតភាពនៃផលចំណេញ<br>ប្រសិទ្ធភាពនៃការប្រើប្រាស់សារធាតុចិញ្ចឹម<br>ការបំភាយឧស្ម័នផ្ទះកញ្ចក់ | ជម្រើសជីអសរីរាង្គ<br>ជីអសរីរាង្គអាចត្រូវបានប្រើប្រាស់តែក្នុងករណីដែលជីទាំងនោះត្រូវបានចុះបញ្ជីត្រឹមត្រូវ និងជាជីមកពីប្រភពគួរជាទីទុកចិត្តប៉ុណ្ណោះ។ | a) មិនមានការប្រើប្រាស់ជីអសរីរាង្គ (គីមី)។ | ៣ |
| | | | b) កសិករប្រើប្រាស់ជីអសរីរាង្គដែលត្រូវបានចុះបញ្ជីត្រឹមត្រូវ និងជាជីមកពីប្រភពមិនក្លែងបន្លំ។ | ៣ * |
| | | | c) កសិករប្រើប្រាស់ជីអសរីរាង្គដែលមិនបានចុះបញ្ជីត្រឹមត្រូវ និងមកពីប្រភពក្លែងបន្លំ។<br> | ០ |

| | | | | |
|---|---|---|---|---|
| | | | | |
| **ការគ្រប់គ្រងកត្តាចង្រៃ** | | | | |
| ១៨.១ | ផលិតភាពនៃ<br>ផលចំណេញ<br>ជីវចម្រុះ<br>សុវត្ថិភាពអាហារ | **ការគ្រប់គ្រងស្មៅចង្រៃ**<br>វិធីសាស្ត្របង្ការកុំឱ្យមានស្មៅចង្រៃរួមមាន៖<br>• ការរៀបចំដីឱ្យបានល្អ<br>• ការប្រើប្រាស់គ្រាប់ពូជដែលបានបញ្ជាក់<br>• ការដាំដំណាំបង្វិល<br>• ពន្លិចទឹក (ប្រសិនបើទឹកមានច្រើន)។<br><br>កសិករអនុវត្តតាមគោលការណ៍ IPM និងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖<br>1. វិធីសាស្ត្របង្ការកុំឱ្យមានស្មៅចង្រៃត្រូវបានប្រើ មុនពេលពិចារណារកវិធីសាស្ត្រផ្សេងកម្ចាត់ ។<br>2. ថ្នាំសំលាប់ស្មៅត្រូវបានប្រើលុះត្រាតែការប្រើវិធីសាស្ត្រកម្ចាត់ស្មៅចង្រៃ (ឧ. ការកម្ចាត់ដោយដៃ ឬដោយមេកានិក) មិនមែនប្រសិទ្ធភាព ហើយភាពធ្ងន់ធ្ងរនៃស្មៅត្រូវបានគេរំពឹងថានឹងបង្កឱ្យមានការខូចខាត ឬការបាត់បង់ច្រើនគួរឱ្យកត់សម្គាល់។<br>3. ការជ្រើសរើសថ្នាំសំលាប់ស្មៅគឺសមស្របតាមការណែនាំរបស់រដ្ឋាភិបាល ហើយបានចុះបញ្ជីសម្រាប់ប្រើលើស្រូវ, បានមកពីប្រភពមិនក្លែងក្លាយ និងមិនមាននៅក្នុងបញ្ជីអន្តរជាតិដូចខាងក្រោម៖<br>✓ ការបំពុលដោយសារជាតុគីមីសរីរាង្គ (POP) ដូចមាននៅក្នុងអនុសញ្ញាស្តុកខុម<br>✓ 1A ឬ B1 ក្នុងចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក<br>✓ ឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញារ៉ូទ័រដាំ។ | a) គ្មានការប្រើប្រាស់វិធីសាស្ត្រកម្ចាត់ស្មៅ (បន្ទាប់ពីប្រើប្រាស់វិធីសាស្ត្របង្ការកុំឱ្យមានស្មៅ)។<br><br>វិធីសាស្ត្រកម្ចាត់ស្មៅត្រូវបានអនុវត្ត និង<br>b) កសិករគ្រប់គ្រងស្មៅយ៉ាងមានប្រសិទ្ធភាព ដោយមិនប្រើប្រាស់ថ្នាំគីមីកម្ចាត់ស្មៅ។<br><br>c) កសិករអនុវត្តតាមគោលការណ៍ IPM ទាំង ៦ ដូចបានបង្ហាញ។<br><br>d) កសិករអនុវត្តគោលការណ៍ IPM ចំនុច ១, ២, ៣, ៤ និង៥ ប៉ុណ្ណោះ។<br><br>e) កសិករអនុវត្តគោលការណ៍ IPM ចំនុច ១, ២, និង ៣ ប៉ុណ្ណោះ។<br><br>f) កសិករមិនបានអនុវត្ត គោលការណ៍ ១,២ និង ៣។ | ៣<br><br>៣<br><br>៣<br><br>២ *<br><br>១<br><br>0 |

| | | | | |
|---|---|---|---|---|
| | | 4. ការប្រើប្រាស់ថ្នាំកម្ចាត់ស្មៅត្រូវឱ្យចំគោលដៅ ជៀសវាងប៉ះពាល់ដល់តំបន់មិនប្រើប្រាស់ថ្នាំ កសិកម្ម។<br>5. វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់ស្មៅគឺយោងទៅតាមសេចក្តីណែនាំស្លាកផលិតផល ចន្លោះពេលប្រមូលផល និងមិនលើសពីកម្រិតប្រើប្រាស់ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ) ។<br>6. ការជ្រើសរើស និងប្រើប្រាស់ថ្នាំកម្ចាត់ស្មៅត្រូវឱ្យចំប្រភេទស្មៅគោលដៅ ពិចារណាលើការកំណត់ពេលវេលាសមស្រប និងពិនិត្យលើភាពស៊ាំនៃថ្នាំ (សម្រាប់ប្រសិទ្ធភាព)។ | | |
| ១៨.២ | ផលិតភាពនៃផលចំណេញ<br>ជីវចម្រុះ<br>សុវត្ថិភាពអាហារ | **វិធានការគ្រប់គ្រងសត្វល្អិត**<br>វិធីសាស្ត្រការពារសត្វល្អិតរួមមាន៖<br>• ប្រើប្រាស់សារធាតុចិញ្ចឹមឱ្យមានតុល្យភាព (ឧ.ជៀសវាងប្រើជីអាសូតលើសកម្រិត)<br>• លើកកំពស់នូវសត្រូវធម្មជាតិមានប្រយោជន៍ (ឧ. សត្វល្អិតមានប្រយោជន៍ ពីងពាង) និង បង្កើនជម្រកជីវចម្រុះនៅជុំវិញវាលស្រែ<br>• ដាំដុះស្រូវឱ្យព្រមគ្នា<br>• ប្រើប្រាស់ពូជស្រូវធន់នឹងសត្វល្អិតនិងជំងឺ<br>• លើកកំពស់ប្រភេទប្រដាក់ទ័រផ្សេងទៀតដូចជា បក្សី ប្រចៀវ និងពពួកកង្កែប<br>• ដាំដំណាំបង្វិល ឬពន្យាររយៈពេលដាំដុះបន្ទាប់។<br>**កសិករអនុវត្តគោលការណ៍** IPM **ដូចខាងក្រោម៖**<br>1. វិធីសាស្ត្រការពារកុំឱ្យមានសត្វល្អិតត្រូវបានប្រើ មុនពេលពិចារណាលើវិធី | a) គ្មានប្រើវិធីសាស្ត្រកម្ចាត់សត្វល្អិតទេ ប្រសិនប្រើវិធីសាស្ត្រការពារសត្វល្អិតមានប្រសិទ្ធភាព។<br>វិធីសាស្ត្រកម្ចាត់សត្វល្អិតល្អិតត្រូវបានប្រើហើយ៖<br>b) កសិករគ្រប់គ្រងសត្វល្អិតយ៉ាងមានប្រសិទ្ធភាពដោយគ្មានប្រើថ្នាំសំលាប់សត្វល្អិត។<br>b) កសិករអនុវត្តតាមគោលការណ៍ទាំង ៧។<br>c) កសិករអនុវត្តតាមគោលការណ៍ ១, ២, ៣, ៤, ៥ និង ៦ ប៉ុណ្ណោះ ។<br>d) កសិករអនុវត្តតាមគោលការណ៍ ១, ២, ៣ និង ៤ ប៉ុណ្ណោះ។<br>f) កសិករមិនបំពេញតាមគោលការណ៍ ១, ២, ៣ និង ៤ ទេ ។ | ៣<br>៣<br>៣<br>២*<br>១<br>0 |

| | | | | |
|---|---|---|---|---|
| | | សាស្ត្រកម្ចាត់បន្ត។<br>2. ថ្នាំសំលាប់សត្វល្អិតត្រូវបានប្រើលុះត្រាតែវិធីសាស្ត្រកម្ចាត់ដទៃទៀត (ឧ. សារជាតុទាក់ទាញសត្វល្អិត ភ្នាក់ងារជីវសាស្ត្រ) មិនមានប្រសិទ្ធភាព ហើយកម្រិតបំផ្លាញលើសដែនកំណត់ ឬវត្តមានសត្វល្អិតបំផ្លាញមាន ច្រើន និងបណ្តាលឱ្យខូចខាតដំណាំ។<br>3. ថ្នាំសំលាប់សត្វល្អិតវិសាលគមមិនត្រូវបានប្រើទេ ក្នុងរយៈពេល ៤០ ថ្ងៃ ដំបូង បន្ទាប់ពីដាំ (លុះត្រាតែអនុលោមតាមជាមួយនឹងការណែនាំ IPM ដែលបានផ្តល់ដោយអ្នកជំនាញ។<br>4. ការជ្រើសរើសថ្នាំសំលាប់សត្វល្អិតគឺស្របនឹងអនុសាសន៍របស់រដ្ឋាភិបាល និងជាថ្នាំបានចុះបញ្ជីទទួលស្គាល់សម្រាប់ប្រើក្នុងផលិតកម្ម ស្រូវ  បាន មកពីប្រភពមិនក្លែងក្លាយ និងមិនមាននៅក្នុងបញ្ជីអន្តរជាតិដូចខាង ក្រោម:<br>✓ ការបំពុលដោយសារជាតុគីមីសរីរាង្គ (POP) ដូចមាននៅក្នុងអនុ សញ្ញាស្តុកខុម<br>✓ 1A ឬ B1 ក្នុងចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក<br>✓ ឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញារ៉ូទ័រដាំ។<br>5. ការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតត្រូវឱ្យចំគោលដៅ ជៀសវាងប្រើនៅ តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។<br>6. វិធីសាស្ត្រនៃការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតគឺយោងទៅតាមសេចក្តី ណែនាំលើស្លាកផលិតផល(ចន្លោះពេលប្រមូលផល មិនលើសពីកម្រិត កំណត់ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ) ។<br>7. ការជ្រើសរើស និងប្រើថ្នាំសំលាប់សត្វល្អិតត្រូវឆ្លើយតបទៅនឹងប្រភេទ | | |

| | | | | |
|---|---|---|---|---|
| | | សត្វល្អិតគោលដៅ ការកំណត់ពេលវេលាសមស្រប និងពិចារណាលើព័ត៌មានក្នុងស្រុកស្តីពីសត្វល្អិតដែលស៊ាំនឹងថ្នាំកម្ចាត់សត្វល្អិត (សម្រាប់ប្រសិទ្ធភាព)។ | | |
| ១៨.៣ | | ***ការគ្រប់គ្រងជំងឺ***<br><br>វិធីសាស្ត្រគ្រប់គ្រងការពារជម្ងឺរួមមាន( មានប្រសិទ្ធភាពសម្រាប់ដោយផ្សិត បាក់តេរី និងវីរុស)៖<br><br>- ប្រើសារធាតុចិញ្ចឹមឲ្យមានតុល្យភាព (ជៀសវាងការប្រើប្រាស់ជីអាសូតលើសកម្រិត)<br>- ដាំដុះដោយមានដង់ស៊ីតេដំណាំសមស្រប<br>- ប្រើប្រាស់ពូជធន់<br>- ដាំដុះស្របពេលគ្នា<br>- ដករុក្ខជាតិជាជំរកចេញ (ស្មៅចង្រៃនៅលើភ្លឺ ស្រូវមួរ ឬស្រូវដុះខ្លួនឯង)<br>- រក្សាបរិស្ថានល្អរវាងដី និងគម្របរបស់ដំណាំ ទាំងលក្ខខណ្ឌស្ងួត ឬសើម (អាស្រ័យលើប្រភេទជម្ងឺ)។<br><br>កសិករអនុវត្តតាមគោលការណ៍ IPM និងតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖<br><br>1. ប្រសិនបើអាចធ្វើបាន ត្រូវអនុវត្តវិធីសាស្ត្រមិនប្រើជាតិគីមី<br>2. ថ្នាំកម្ចាត់ផ្សិតត្រូវបានប្រើវិធីសាស្ត្រគ្រប់គ្រងការពារជំងឺដូចជា ប្រើប្រាស់ភ្នាក់ងារជីវសាស្ត្រ មិនមានប្រសិទ្ធភាព ហើយការបំផ្លាញដំណាំធ្ងន់ធ្ងរ។<br>3. ការជ្រើសរើសថ្នាំកម្ចាត់ផ្សិតគឺស្របនឹងអនុសាស្ត្ររបស់រដ្ឋាភិបាល និងជាថ្នាំបានចុះបញ្ជីត្រឹមត្រូវ មិនមែនពីប្រភពក្លែងបន្លំ ហើយមិនមាននៅក្នុងបញ្ជីអន្តរជាតិដូចខាងក្រោម៖<br>✓ ការបំពុលដោយសារធាតុគីមីសរីរាង្គ (POP) ដូចមាននៅក្នុង | a) គ្មានប្រើប្រាស់វិធីសាស្ត្រកម្ចាត់ជម្ងឺទេដោយកសិករអនុវត្តវិធីសាស្ត្រគ្រប់គ្រងការពារជម្ងឺមានប្រសិទ្ធភាព។<br><br>វិធីសាស្ត្រកម្ចាត់សត្វល្អិតត្រូវបានអនុវត្ត ហើយ៖<br>b) កសិករគ្រប់គ្រងជម្ងឺយ៉ាងមានប្រសិទ្ធភាដោយគ្មានការប្រើថ្នាំកម្ចាត់ផ្សិត។<br><br>c) កសិករអនុវត្តតាមគោលការណ៍ទាំង ៦ចំនុច។<br><br>d) កសិករអនុវត្តតាមគោលការណ៍ទី ១, ២, ៣, ៤ និង ៥ ។<br>e) កសិករអនុវត្តតាមគោលការណ៍ទី ១ ២ និង៣។<br><br>f) កសិករមិនអនុវត្តតាមគោលការណ៍ទី ១, ២ និង ៣។ | ៣<br><br>៣<br><br>៣<br><br>២ *<br><br>១<br><br>0 |

| | | | | |
|---|---|---|---|---|
| | | អនុសញ្ញាស្តុកខុម<br>✓ ☐ស្ម B1 ក្នុងចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក<br>✓ ☐ឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញារ៉ូទ័រដាំ។<br>4. ថ្នាំកម្ចាត់ផ្សិតត្រូវប្រើឱ្យចំគោលដៅ ជៀសវាងប្រើប្រាស់ប៉ះពាលតំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។<br>5. វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់ផ្សិតត្រូវអនុវត្តតាមការណែនាំលើផ្លាកផលិតផល ចន្លោះពេលប្រមូលផល ឬទុករយៈពេល៣០ថ្ងៃមុនពេលប្រមូលផល មិនប្រើប្រាស់លើកម្រិតណែនាំ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ)។<br>6. ថ្នាំកម្ចាត់ផ្សិតត្រូវប្រើឱ្យចំប្រភេទជម្ងឺ ដោយពិចារណាលើប្រវត្តិថ្មីនៃជម្ងឺបង្កដោយផ្សិត និងព្យាករណ៍លក្ខណៈអាកាសធាតុ និងព័ត៌មានជម្ងឺដែលស៊ាំនឹងថ្នាំកម្ចាត់ផ្សិតនៅក្នុងមូលដ្ឋាន (សម្រាប់ប្រសិទ្ធភាព) | | |
| ១៨.៤ | | **ការគ្រប់គ្រងសប្បឹសត្វ (ពពួកខ្យង)**<br>វិធីសាស្ត្រគ្រប់គ្រងពពួកខ្យងដោយមិនប្រើសារធាតុគីមីមាន៖<br>- ការគ្រប់គ្រងបែបរូបវន្ត (ការបំផ្លាញពង ការរើសខ្យង ខ្ចៅដោយដៃ)<br>- បន្ថយកំពស់ទឹកនៅដំណាក់កាលលូតលាស់ដំបូង<br>- ប្រើប្រាស់ និងជំរុញឱ្យមានពពួកប្រដាក់ទ័រ (ឧ. បក្សីព្រៃ ទា និងត្រី)<br>- ប្រើប្រាស់សំណាបចាស់សម្រាប់ស្ទូងដោយសាបមិនញឹកពេក និងស្ទូងសំណាបចាស់<br>- ផ្លាស់មុខដំណាំឬទុកចន្លោះពេលមិនដាំដុះយូរជាងមុន។<br>កសិករអនុវត្តតាមគោលការណ៍ IPM និងតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖ | a) គ្មានប្រើប្រាស់វិធីសាស្ត្រកម្ចាត់ពពួកខ្យងទេ ដោយកសិករអនុវត្តវិធីសាស្ត្រគ្រប់គ្រងការពារពពួកខ្យងមានប្រសិទ្ធភាព។<br>**វិធីសាស្ត្រកម្ចាត់ពពួកខ្យងត្រូវបានអនុវត្ត ហើយ៖**<br>b) កសិករគ្រប់គ្រងពពួកខ្យងយ៉ាងមានប្រសិទ្ធភាពដោយគ្មានការប្រើថ្នាំកម្ចាត់ពពួកខ្យង។<br>c) កសិករអនុវត្តតាមគោលការណ៍ទាំង ៦ចំនុច។<br>d) កសិករអនុវត្តតាមគោលការណ៍ទី ១, ២, ៣, ៤ | ៣<br>៣<br>៣<br>២ * |

| | | | | |
|---|---|---|---|---|
| | | 1. វិធីសាស្ត្រការពារពពួកខ្យងត្រូវបានប្រើ មុនពេលជ្រើសរើសវិធីសាស្ត្រកម្ចាត់ពពួកខ្យង។<br><br>2. ថ្នាំកម្ចាត់ពពួកខ្យងត្រូវបានប្រើ តែប្រសិនបើវិធីសាស្ត្រកម្ចាត់ផ្សេង (ឧ. ប្រមូល) មិនមានប្រសិទ្ធភាព ហើយវត្តមានសត្វបំផ្លាញលើលកម្រិត ដែលបណ្តាលឱ្យប៉ះពាល់ធ្ងន់។<br><br>3. ការជ្រើសរើសថ្នាំកម្ចាត់ពពួកខ្យង គឺសមស្របនឹងអនុសាសន៍របស់រដ្ឋាភិបាល និងបានចុះបញ្ជីសម្រាប់ប្រើក្នុងផលិតកម្មស្រូវ និងបានមកពីប្រភពមិនក្លែងក្លាយ និងមិនមានក្នុងបញ្ជីអន្តរជាតិដូចខាងក្រោម៖<br>✓ ការបំពុលដោយសារធាតុគីមីសរីរាង្គ (POP) ដូចមាននៅក្នុងអនុសញ្ញាស្តុកខុម<br>✓ A1 ឬ B1 ក្នុងចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក<br>✓ ឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញារ៉ូទ័រដាំ។<br>4. ការប្រើប្រាស់ថ្នាំកម្ចាត់ពពួកខ្យងត្រូវប្រើប្រាស់ឱ្យចំគោលដៅ ជៀសវាងប៉ះពាល់តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។<br>**5.** វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់ពពួកខ្យងត្រូវអនុវត្តតាមការណែនាំលើផ្លាកផលិតផល  មិនត្រូវប្រើមុនពេលស្ទូងដោយដៃទេ ទុកចន្លោះពេលប្រមូលផល និងមិនប្រើប្រាស់លើកម្រិតណែនាំ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ)។<br>6. ថ្នាំកម្ចាត់ពពួកខ្យងត្រូវប្រើឱ្យចំប្រភេទសិប្បីសត្វ និងត្រូវប្រើប្រាស់តែនៅរយៈពេល៣ សប្តាហ៍ដំបូងបន្ទាប់ពីការដាំដុះដំណាំ។ | និង ៥ ។<br><br>**e)** កសិករអនុវត្តតាមគោលការណ៍ទី ១ ២ និង៣។<br><br>**f)** កសិករមិនអនុវត្តតាមគោលការណ៍ទី ១, ២ និង ៣។ | <br><br>១<br><br>0 |

| | | | | |
|---|---|---|---|---|
| ១៨.៥ | | *ការគ្រប់គ្រងសត្វកណ្ដុរ*<br><br>**វិធីសាស្ត្រគ្រប់គ្រងសត្វកណ្ដុរដោយមិនប្រើជាតិគីមីរួមមាន៖**<br><br>- គ្រប់គ្រងសត្វកណ្ដុរជាសហគមន៍ (ឧ. យុទ្ធនាការលុបបំបាត់កណ្ដុរ ដំណាំអន្ទាក់)<br>- ដាំដុះដំណាំស្របពេលគ្នា<br>- ធ្វើភ្លឺស្រែឱ្យតូច (កាត់បន្ថយជម្រកកណ្ដុរ)<br>- ថែរក្សាសត្វស៊ីកណ្ដុរ (បក្សីស៊ីកណ្ដុរ ពស់)<br><br>**កសិករអនុវត្តតាមគោលការណ៍** IPM **និងតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖**<br>1. វិធីសាស្ត្រគ្រប់គ្រងកណ្ដុរត្រូវបានប្រើ មុនពេលជ្រើសរើសវិធីសាស្ត្រកម្ចាត់កណ្ដុរ។<br><br>2. ថ្នាំកម្ចាត់កណ្ដុរត្រូវបានប្រើ ប្រសិនបើវិធីសាស្ត្រកម្ចាត់ផ្សេង (ឧ. ដាក់អន្ទាក់ប្រមាញ់) មិនមានប្រសិទ្ធភាព ឬមានប្រវត្តិបញ្ហាសត្វកណ្ដុរបំផ្លាញ និងមានវត្តមានសត្វកណ្ដុរច្រើនអាចបណ្ដាលឱ្យមានការបំផ្លាញធ្ងន់ធ្ងរ។<br><br>3. ការជ្រើសរើសថ្នាំកម្ចាត់កណ្ដុរ គឺសមស្របនឹងអនុសាសន៍របស់រដ្ឋាភិបាល និងបានចុះបញ្ជីសម្រាប់ប្រើក្នុងផលិតកម្មស្រូវ និងបានមកពីប្រភពមិនក្លែងក្លាយ និងមិនមានក្នុងបញ្ជីអន្តរជាតិដូចខាងក្រោម៖<br><br>✓ ការបំពុលដោយសារជាតុគីមីសរីរាង្គ (POP) ដូចមាននៅក្នុងអនុសញ្ញាស្តុកខុម<br>✓ A1 **ឬ** B1 ក្នុងចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក<br>✓ ឧបសម្ព័ន្ធទី ៣ នៃអនុសញ្ញារ៉ូទ័រដាំ។<br>4. ការប្រើប្រាស់ថ្នាំកម្ចាត់កណ្ដុរត្រូវប្រើប្រាស់ឱ្យចំគោលដៅ ជៀសវាងប៉ះពាល់ | a) គ្មានប្រើប្រាស់វិធីសាស្ត្រកម្ចាត់កណ្ដុរទេដោយកសិករអនុវត្តវិធីសាស្ត្រគ្រប់គ្រងការពារកណ្ដុរមានប្រសិទ្ធភាព។<br><br>វិធីសាស្ត្រកម្ចាត់កណ្ដុរត្រូវបានអនុវត្ត ហើយ៖<br>b) កសិករគ្រប់គ្រងកណ្ដុរយ៉ាងមានប្រសិទ្ធភាពដោយគ្មានការប្រើថ្នាំកម្ចាត់កណ្ដុរ។<br><br>c) កសិករអនុវត្តតាមគោលការណ៍ទាំង ៦ចំនុច។<br><br>d) កសិករអនុវត្តតាមគោលការណ៍ទី ១, ២, ៣, ៤ និង ៥ ។<br><br>e) កសិករអនុវត្តតាមគោលការណ៍ទី ១, ២ និង៣។<br><br>f) កសិករមិនអនុវត្តតាមគោលការណ៍ទី ១, ២ និង ៣។ | ៣<br><br>៣<br><br>៣<br><br>២ *<br><br>១<br><br>0 |

| | | | | |
|---|---|---|---|---|
| | | តំបន់មិនប្រើប្រាស់ថ្នាំកសិកម្ម។<br>**5.** វិធីសាស្ត្រប្រើប្រាស់ថ្នាំកម្ចាត់កណ្តុរត្រូវអនុវត្តតាមការណែនាំលើផ្លាកផលិតផល ទុកចន្លោះពេលប្រមូលផល និងមិនប្រើប្រាស់លើកម្រិតណែនាំ (សម្រាប់សុវត្ថិភាពកម្មករ និងសុវត្ថិភាពអាហារ)។<br>6. ថ្នាំកម្ចាត់កណ្តុរត្រូវប្រើឱ្យចំប្រភេទសត្វកណ្តុរ និងប្រើប្រាស់មុនពេលបង្កបង្កើនផល ជៀសវាងការផ្ទុះការបំផ្លាញនៅក្នុងដំណាក់កាលដាក់គ្រាប់ ហើយគួរដាក់នៅក្រោមគម្របការពារ ឧ. បំពង់ឫស្សី ឬត្រឡោកដូង ដែលបក្សីមិនងាយចូលទៅស៊ីបាន ហើយមិនងាយត្រូវទឹកភ្លៀង (សម្រាប់ប្រសិទ្ធភាព)។ | | |
| ១៨.៦ | | *ការគ្រប់គ្រងបក្សី*<br><br>**ជម្រើសការគ្រប់គ្រងបក្សីដោយមិនសម្លាប់មានដូចជា៖**<br>- ដាំដុះស្របពេលគ្នា<br>- ប្រើឧបករណ៍បន្លាច/បំភ័យ<br>ថែរក្សាសត្វមានប្រយោជន៍ ដែលស៊ីបក្សី (ឧ. បក្សីស៊ីសត្វស្លាប បក្សីស្រែក (shrikes))។ | a) គ្មានការគ្រប់គ្រងបក្សីត្រូវបានអនុវត្ត<br>ការគ្រប់គ្រងបក្សីត្រូវបានអនុវត្ត ហើយ៖<br>b) បក្សីត្រូវបានគ្រប់គ្រងដោយវិធីសាស្ត្រមិនសម្លាប់។<br>c) បក្សីត្រូវបានគ្រប់គ្រងដោយការដាក់អន្ទាក់រស់ ហើយបក្សីទាំងអស់ត្រូវបានលែងទាំងរស់ទៅវិញ<br>d) បក្សីត្រូវបានគ្រប់គ្រងដោយការប្រមាញ់ដោយរើសប្រភេទសត្វបំផ្លាញ។<br>e) បក្សីត្រូវបានសម្លាប់មិនរើសមុខ ដោយការសម្លាប់ ការដាក់ថ្នាំពុល ឬការប្រមាញ់ ។ | ៣<br>៣<br>២<br>១*<br>0 |

| | | | | |
|---|---|---|---|---|
| **ការប្រមូលផលនិងក្រោយប្រមូលផល** | | | | |
| ១៩ | ផលចំណេញ<br><br>ផលិតភាព<br><br>សុវត្ថិភាពអាហារ | **ការកំណត់ពេលប្រមូលផល**<br><br>ដំណាំស្រូវត្រូវបានប្រមូលផលតាមពេលវេលាសមស្របដើម្បីបង្កើនគុណភាពគ្រាប់ស្រូវជាអតិបរមា<br>**ការណែនាំទូទៅក្នុងការកំណត់ពេលវេលាសមស្របប្រមូលផល**<br>១. គ្រាប់ស្រូវមានសភាពកួរស្រូវទុំពី ៨០-៨៥%មានពណ៌លឿង ឬ ដូចចំបើង<br>២. គ្រាប់ស្រូវមានអត្រាសំណើមចន្លោះពី២១% ទៅ ២៤%<br>៣. គ្រាប់ស្រូវទុំនៅចន្លោះពី២៨ និង៣៥ថ្ងៃបន្ទាប់ពីចេញផ្កាចំពោះស្រូវប្រាំង និងចន្លោះពី៣២ ទៅ៣៨ថ្ងៃបន្ទាប់ពីចេញផ្កាចំពោះស្រូវវស្សា។<br>៤. ចន្លោះពី១៣០ ទៅ១៣៦ថ្ងៃបន្ទាប់ពីព្រួសសម្រាប់ពូជស្រូវធ្ងន់ ចន្លោះ១១៣ ទៅ១២៥ថ្ងៃសម្រាប់ពូជស្រូវកណ្ដាល និង១១០ថ្ងៃសម្រាប់ស្រាលនៃថ្ងៃចាប់ផ្ដើមទុំ។<br>៥. គ្រាប់ស្រូវនៅគល់កួរមានសភាពរឹង (រឹងប៉ុន្តែមិនងាយបាក់) គ្រាប់ស្រូវដែលយើងកាន់មានសភាពសើមខ្លាំង ។ | a) កសិករអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី១ ឬ ២។<br><br>b) កសិករអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី៣ ឬ ៤។<br><br>c) កសិករអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី៥។<br><br>d/ មិនបានអនុវត្តតាមខាងលើទាំងអស់ | ៣<br><br>២ *<br><br>១<br><br>0 |
| | សុវត្ថិភាពអាហារ | **ឧបករណ៍ប្រមូលផល**<br>ស្រូវត្រូវបានប្រមូលផលដោយឧបករណ៍ស្អាត ដើម្បីការពារកុំឲ្យមានការចម្លងជំងឺ និងការលាយចូលប្រភេទពូជស្រូវផ្សេងទៀត។ | សម្រាប់ការប្រមូលផលដោយដៃ<br>a) ឧបករណ៍ធុនធ្ងន់ត្រូវបានសម្អាតមុនពេលប្រើប្រាស់ | ៣ * |

| | | | | |
|---|---|---|---|---|
| | | ក្នុងករណីប្រើប្រាស់ម៉ាស៊ីនច្រូត ត្រូវមានការកែតម្រូវ កំណត់និងដំណើរការឲ្យបានល្អបំផុតដោយផ្អែកលើប្រភេទដំណាំ និងស្ថានភាពដីស្រែដែលធ្វើយ៉ាងណាឲ្យការបាត់បង់គុណភាព និងការបែកបាក់គ្រាប់ស្រូវនៅសល់ជាអប្បរមា។ | b) ឧបករណ៍ធុនធ្ងន់មិនត្រូវបានសម្អាតមុនពេលប្រើប្រាស់<br>សម្រាប់ការប្រមូលផលដោយម៉ាស៊ីន | ០ |
| | | | c) ឧបករណ៍ធុនធ្ងន់ត្រូវបានសម្អាតមុនពេលប្រើប្រាស់ ហើយមុខងារម៉ាស៊ីនត្រូវបានកែសម្រួល | ៣ * |
| | | | d) ទាំងឧបករណ៍ប្រមូលផលត្រូវបានសម្អាតមុនយកទៅប្រើឬទាំងមុខងារម៉ាស៊ីនត្រូវបានកែសម្រួល | ១ |
| | | | e) ទាំងឧបករណ៍ប្រមូលផលមិនត្រូវបានសម្អាតមុនយកទៅប្រើ និងទាំងមុខងារម៉ាស៊ីនមិនត្រូវបានកែសម្រួល<br> | ០ |
| ២១ | ផលចំណេញ<br>ផលិតភាព<br>សុវត្ថិភាពអាហារ | **ពេលវេលាហាលសម្ងួត**<br>ការហាលសម្ងួតស្រូវនៅស្រែក្នុងរយៈពេល២៤ម៉ោងក្រោយពេលប្រមូលផល។ ត្រូវកត់ត្រាសំណើមចុងក្រោយ ហើយសំណើមគ្រាប់ស្រូវអាស្រ័យលើការប្រើប្រាស់៖<br>- សំណើម១៤-១៨% សម្រាប់ការលក់ដោយផ្ទាល់តែក្នុងរយៈពេល៣ថ្ងៃ<br>- សំណើម១៦% ឬតិចជាង សម្រាប់ការលក់តែម្តងក្នុងរយៈពេល១សប្តាហ៍<br>- សំណើម១៤% ឬតិចជាង សម្រាប់គ្រាប់ស្រូវស្តុកទុកយូរជាង១សប្តាហ៍ | a) កសិករបានដឹកស្រូវទៅកាន់កន្លែងសម្ងួត ឬកន្លែងកែច្នៃក្នុងរយៈពេល១២ម៉ោងក្រោយពេលប្រមូលផល | ៣ |
| | | | b) កសិករបានចាប់ផ្តើមសម្ងួតនៅនឹងស្រែក្នុងរយៈពេល២៤ម៉ោងក្រោយពេលប្រមូលផលដោយហួតដល់សំណើម១៦% ឬតិចជាងនេះ និងសំណើមមិនលើសពី១% សំណើមជម្រាលក្នុង១សប្តាហ៍។ | ៣ |

| | | | | |
|---|---|---|---|---|
| | | - សំណើម១២% ឬតិចជាង សម្រាប់គ្រាប់ស្រូវស្តុកទុកធ្វើពូជ<br>សំណើមគ្រាប់ស្រូវគេដាគំនរ មិនអាចលើសពី១% បន្ទាប់ពីហាលសម្ងួតបើប្រៀបធៀបនឹងសំណើមមធ្យម (សំណើមទីជម្រាល)។<br><br>ប្រសិនបើមិនហាលសម្ងួតស្រូវនៅស្រែទេ (ឧ. ទីធ្លារចាក់បេតុងរបស់កសិករ) ត្រូវដឹកស្រូវទៅសម្ងួតនៅ (ឧ. រោងម៉ាស៊ីន) ឬ កន្លែងកែច្នៃក្នុងរយៈពេល១២ម៉ោងក្រោយពេលប្រមូលផល។ | c) កសិករចាប់ផ្តើម សម្ងួតនៅស្រែក្នុងរយៈពេល២៤ម៉ោងក្រោយពេលប្រមូលផល និងទុកហូតសំណើម១៤-១៨% ឬតិចជាងនេះ និងសំណើមមិនលើសពី១% សំណើមជម្រាលក្នុងរយៈពេល៣ថ្ងៃ។ | ២ * |
| | | | d) កសិករចាប់ផ្តើម សម្ងួតនៅស្រែក្នុងរយៈពេល២៤ម៉ោងក្រោយពេលប្រមូលផល ប៉ុន្តែមិនអាចកត់ត្រាសំណើម១៨% ឬតិចជាងនេះឬមិនដល់១% ឬតិចជាងសំណើមទីជម្រាល។ | ១ |
| | | | e)កសិករមិនដឹកស្រូវទៅកន្លែងសម្ងួត ឬកែច្នៃ ក្នុងរយៈពេល១២ម៉ោងបន្ទាប់ពីប្រមូលផលរួម ឬចាប់ផ្តើមហាលស្ងួតស្រូវនៅស្រែក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីប្រមូលផល។  | 0 |
| ២២ | ផលចំណេញ<br>ផលិតភាព<br>សុវត្ថិភាពអាហារ | **បច្ចេកទេសសម្ងួត**<br>ស្រូវត្រូវបានសម្ងួតដោយប្រើប្រាស់បច្ចេកទេសសម្ងួតប្រកបដោយនិរន្តរភាព។<br><br>សម្រាប់ហាលសម្ងួតដោយកំដៅ៖<br>១. កម្រាស់ស្រូវគឺ២-៤ស.មនិង<br>២. ស្រូវគឺត្រូវវិត្រឡប់អោយបានទៀងទាត់<br>៣. ការពារគ្រាប់ស្រូវកុំឲ្យប៉ះទឹកភ្លៀង | a) មិនមានការសម្ងួតដោយខ្លួនគាត់ផ្ទាល់ទេ | n/a |
| | | | b) កសិករប្រើម៉ាស៊ីនសម្ងួតអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី៥ និង៦។ | ៣ |
| | | | c) សម្ងួតដោយកំដៅថ្ងៃដោយអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី១,២,៣ និង៤។ | ២ * |
| | | | d) សម្ងួតដោយកំដៅថ្ងៃដោយអនុវត្តតាមលក្ខណៈវិនិច្ឆ័យទី៣ និង៤។ | ១ |

| | | | | |
|---|---|---|---|---|
| | | ៤. គ្រាប់ស្រូវត្រូវការពារពីជំងឺផ្សិត ការយាយីពីសកម្មភាព (មីកូតុកស៊ីន) ស្បៃ កន្ទេល ផ្ទាំង តង់ ) មនុស្ស សត្វ ដើរជាន់លើជាដើម)<br><br>សម្រាប់ការសម្ងួតដោយឡ៖<br>៥. ប្រើប្រាស់ឡសម្ងួត ដែលបានបញ្ជាក់គុណភាព ដើម្បីផលិតគ្រាប់ស្រូវមានគុណភាពល្អបំផុតមិន) ប្រែពណ៌ គ្មានក្លិន មានអត្រាគ្រាប់អង្ករបាក់)<br>៦. កំណត់ឡសម្ងួតកំដៅអតិប្បរមាមិនខ្ពស់ជាង៤៣អង្សាសេ សម្រាប់ឡសម្ងួតផ្តេក និង មិនលើសពី៥៥អង្សាសេ សម្រាប់ឡសម្ងួតវិលជុំ។ | e) មិនបានអនុវត្តតាមលក្ខណៈវិនិច្ឆ័យទាំងអស់។ | 0 |
| ២៣ | ផលចំណេញ ផលិតភាព សុវត្ថិភាពអាហារ | **ការស្តុកស្រូវ**<br>ស្រូវត្រូវបានស្តុកទុកយ៉ាងមានសុវត្ថិភាពរក្សាគុណភាពតាមរយៈការស្តុកបិទជិត ឬ វិធានការខាងក្រោម៖<br>1. ការពារការចម្លងជំងឺ ដោយសារសារធាតុគ្រោះថ្នាក់ ដូចជាថ្នាំពុលគីមី<br>2. រក្សាសំណើមគ្រាប់ស្រូវ១៤% ឬ តិចជាង<br>3. ជៀសវាងធ្វើឲ្យគ្រាប់ស្រូវសើមទឹកឡើងវិញ<br>4. ការពារការបំផ្លាញពីសត្វល្អិតចង្រៃ ដោយមិនចាំបាច់ធ្វើភូតគមអនាម័យ បាញ់ ឬដាក់ថ្នាំ))<br>5. គ្រាប់ស្រូវត្រូវបានសម្អាតមុនពេលស្តុកទុក (សំអាត់កាកសំណល់ គ្រាប់ស្មៅ និងសត្វល្អិតចេញ)។ | a) កសិករមិនមានការសម្ងួតនៅកន្លែង។<br>b) កសិករអនុវត្តទុកដាក់បិទ ឬ អនុលោមវិធានការទាំង៥។<br>c) កសិករអនុវត្តតាមតែវិធានការលេខ១, ២,៣ និង៤ប៉ុណ្ណោះ។<br>d) កសិករអនុវត្តវិធានការតាមតែលេខ១ និង២ ប៉ុណ្ណោះ។<br>e) មិនមែនអនុវត្តតាមវិធានការខាងលើទេ។<br> | គ្មាន<br>៣<br>២<br>១ *<br>0 |
| ២៤ | ការប្រើប្រាស់សារធាតុចិញ្ចឹមប្រសិទ្ធភាព | **ជញ្ជ្រាំងស្រូវ**<br><br>ជញ្ជ្រាំងស្រូវត្រូវបានគ្រប់គ្រងតាមវិធីប្រកបដោយនិរន្តរភាពដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងដើម្បីរក្សាឬកែលម្អ | a) កសិករបំពេញតាមលក្ខខណ្ឌទី១ និង២ ដោយមិនភ្ជួរលុបជញ្ជ្រាំងស្រូវចូលក្នុងដីទេ។<br>b) កសិករបំពេញតាមលក្ខខណ្ឌទី១ និង២ ដោយភ្ជួរលុបជញ្ជ្រាំស្រូវនៅពេលដីស្ងួត។ | ៣<br>២ |

| | | | | |
|---|---|---|---|---|
| | ការបំភាយ ឧស្ម័នផ្ទះ កញ្ចក់ GHG | គុណភាពដី។<br>ជញ្ជ្រាំងស្រូវ៖<br>១. មិនត្រូវដុត<br>២. រក្សាទុកបានសមស្រប យ៉ាងតិចឱ្យបាន៣សប្តាហ៍ ដើម្បីឲ្យរលួយពុកផុយមុនពេលបញ្ចូលទឹក ឬភ្ជួរលុប។ | c) កសិករបំពេញលក្ខខណ្ឌទី១ ប៉ុន្តែភ្ជួរលុបជញ្ជ្រាំស្រូវនៅពេលដីលិចទឹក។<br>d) កសិករដុតជញ្ជ្រាំងស្រូវ<br> | ១ *<br>០ |
| ២៥ | ការប្រើប្រាស់ សារជាតុចិញ្ចឹម ប្រសិទ្ធភាព ការបំភាយ ឧស្ម័នផ្ទះ កញ្ចក់ GHG | **ចំបើងស្រូវ**<br><br>ចំបើងត្រូវបានគ្រប់គ្រងតាមវិធីសាស្ត្រប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងរក្សា ឬបង្កើនដីជាតិឲ្យប្រសើរឡើង។<br>ចំបើងស្រូវគឺ៖<br>១. មិនត្រូវដុត<br>២. រក្សទុកពេលវេលាឲ្យបានគ្រប់គ្រាន់ (យ៉ាងតិចបំផុត២សប្តាហ៍) ដើម្បីឱ្យចំបើងពុកផុយ ប្រសិនបើចំបើងនៅសល់ក្នុងស្រែគឺត្រូវភ្ជួរលុបក្នុងដី<br>៣. ប្រមូលយកទៅធ្វើជាចំណីសត្វ ហើយលាមកសត្វត្រូវយកមកដាក់ក្នុងស្រែវិញ ឬ ប្រមូលធ្វើជីកំប៉ុស្ត៍ហើយយកមកដាក់ក្នុងស្រែវិញ។ | a) កសិករបំពេញតាមលក្ខខណ្ឌទី១ និង៣។<br>b) កសិករបំពេញលក្ខខណ្ឌទី១ និង២ ប៉ុណ្ណោះ។<br>c) កសិករបំពេញលក្ខខណ្ឌទី១ ប៉ុណ្ណោះ។<br>d) កសិករដុតចំបើងស្រូវ។<br> | ៣<br>២<br>១ *<br>០ |
| **សុខភាពនិងសុវត្ថិភាព** | | | | |
| ២៦ | សុខភាពនិងសុវត្ថិភាពកម្មករ | **ការណែនាំពីសុវត្ថិភាព និងសង្គ្រោះបឋម**<br><br>កម្មករ រួមទាំងសមាជិកគ្រួសារផងដែរទទួលបានការណែនាំជាប្រចាំស្តីពីសុវត្ថិភាព ដើម្បីបង្ការគ្រោះថ្នាក់ឬជំងឺពេល អនុវត្តការងារ និងមានសម្ភារៈ | a) កម្មករ រួមទាំងសមាជិកគ្រួសារដែលធ្វើការ ទទួលបានការណែនាំសុវត្ថិភាពជាប្រចាំ ហើយមានសម្ភារៈសម្រាប់សង្គ្រោះបឋមនៅកន្លែង ឬ ហើយមានសម្ភារៈសម្រាប់សង្គ្រោះបឋមនៅកន្លែង។ | ២ * |

| | | | | |
|---|---|---|---|---|
| | | សម្រាប់សង្គ្រោះបឋមនៅកន្លែង និងរបៀបទំនាក់ទំនងជាមួយមន្ត្រីសុខភាព។ សម្ភារសង្គ្រោះបឋមត្រូវដាក់ស្លាកណែនបានត្រឹមត្រូវ និង នៅក្នុងកសិដ្ឋាន ឬ ទីតាំងបានកំណត់ទទួលស្គាល់ដោយ មជ្ឈមណ្ឌលវេជ្ជសាស្ត្រ និងអាចចូលពិនិត្យសុខភាពក្រុម កសិករបាន។ | b) កម្មករ រួមទាំងសមាជិកគ្រួសារទទួលបានការណែនាំជាប្រចាំស្តីពីសុវត្ថិភាព និងដឹងពីរបៀបទំនាក់ទំនងជាមួយមន្ត្រីសុខភាព។<br>c) ពុំមានការណែនាំអំពីសុវត្ថិភាព ។  | ១ *<br>០ |
| ២៧ | សុខភាពនិងសុវត្ថិភាពកម្មករ | **សម្ភារៈនិងឧបករណ៍**<br>សម្ភារៈនិងឧបករណ៍សម្រាប់ប្រតិការនៅស្រែ និងការកែច្នៃក្រោយពេលការប្រមូលផលកំពុងធ្វើការ ត្រូវបានថែទាំនិងប្រើប្រាស់ និងនិងការក្រិតខ្នាតបានត្រឹមត្រូវជាប្រចាំ។ ឧបករណ៍មានផ្ទុកបានត្រឹមត្រូវ។<br>ឧបករណ៍ប្រើប្រាស់ថ្នាំពុល (ប្រសិនបើប្រើប្រាស់គឺថែទាំ និងវាស់កម្រិតដើម្បីការពារការលេចជ្រាប ឬ ការឆ្លងជំងឺ។ | a) សម្ភារ និងឧបករណ៍បានថែទាំ និងវាស់ក្រិតខ្នាតក្នុងរដូវដាំដុះបច្ចុប្បន្ន។<br>b) សម្ភារ និងឧបករណ៍បានថែទាំ និងវាស់ក្រិតខ្នាតក្នុងរយៈពេលកាលពី២ឆ្នាំមុន។<br>c) សម្ភារ និងឧបករណ៍មិនបានថែទាំ និងវាស់ក្រិតខ្នាតក្នុងរយៈពេលពីរឆ្នាំកន្លងទៅ។<br>  | ២<br>១ *<br>០ |
| ២៨ | សុខភាពនិងសុវត្ថិភាពកម្មករ | **ការបណ្តុះបណ្តាលការប្រើថ្នាំពុលកសិកម្ម**<br><br>អ្នកប្រើថ្នាំពុលកសិកម្មទទួលបានការបណ្តុះបណ្តាល និងអនុវត្តការប្រើបានល្អ ស្តីពីដំណោះស្រាយ និងប្រើប្រាស់ថ្នាំថ្នាំកសិកម្មដោយសុវត្ថិភាព រួមមាន៖<br>• ពន្យល់អំពីឈ្មោះ ការពុល គ្រោះថ្នាំសុខភាព និងពាក់ព័ន្ធព័ត៌មានផ្សេងៗទាក់ទងនឹងសារធាតុពុលដែលត្រូវប្រើ។<br>• បច្ចេកទេសសម្រាប់ដោះស្រាយសារធាតុពុលឲ្យបានត្រឹមត្រូវ។ | a) ពុំមានការប្រើប្រាស់ថ្នាំពុលកសិកម្ម ប្រសិនបានបើប្រើរយៈពេល៥ឆ្នាំមកហើយគឺ៖<br>b) អ្នកប្រើថ្នាំកសិកម្មបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល និង ធ្វើបង្ហាញដែលទាក់ទងនឹង មេរៀនដែលត្រូវអនុវត្ត។<br>c) អ្នកប្រើថ្នាំកសិកម្មបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល។ | ២<br>២<br>១ * |

| | | | | |
|---|---|---|---|---|
| | | • វិធានការបង្ការសម្រាប់កាត់បន្ថយគ្រោះថ្នាក់ដែលអាចកើតមានដល់សុខភាព និងបរិស្ថាន កើតឡើងដោយ សារជាតុល។<br>• វិធានការបន្ទាន់សម្រាប់ករណីទាក់ទងនឹងការពុល ឬប៉ះពាល់សារជាតុពុលើលកម្រិត។ | d) អ្នកប្រើថ្នាំកសិកម្មមិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល។<br>  | ០ |
| ២៩ | សុខភាពនិងសុវត្ថិភាពកម្មករ | **ឧបករណ៍ការពារខ្លួន** (PPE)<br><br>អ្នកប្រើថ្នាំកសិកម្មប្រើប្រាស់ឧបករណ៍ការពារបុគ្គល (PPE) តាមមុខងារ និងមានគុណភាពល្អ តាមការណែនាំនៅលើស្លាកផលិតផល រួមមាន៖<br>- ស្រោមដៃធន់នឹងជាតិគីមី<br>- ម៉ាស់<br>- សម្លៀកបំពាក់ការពារ (ឧ.អាវដៃវែង ខោជើងវែង)<br>- ស្បែកជើងកវែង<br>- វ៉ែនតាការពារភ្នែកក្នុងពេលលាយថ្នាំ និងបាញ់ថ្នាំ<br>  | a) ពុំមានការប្រើប្រាស់ថ្នាំកសិកម្ម<br>**ប្រសិនបើប្រើថ្នាំគឺ៖**<br>b) ក្នុងករណីបាញ់ថ្នាំៈ អ្នកប្រើថ្នាំកសិកម្មប្រើប្រាស់ឧបករណ៍ការពារខ្លួនចំនួន៥មុខក្នុងបញ្ជីដែលបានរៀបរាប់ (ដូចអ្វីដែលបានណែនាំលើស្លាកផលិតផល) ដែលមានគុណភាពល្អ។<br>c) ក្នុងករណីប្រើប្រាស់យន្តហោះ ឬ ដ្រូន ឬ ត្រាក់ទ័របាញ់ថ្នាំៈ អ្នកបាញ់ថ្នាំពុល ប្រើស្រោមដៃ និងម៉ាសក្នុងពេលលាយ(ដូចអ្វីដែលបានណែនាំលើស្លាកផលិតផល) ដែលមានគុណភាពល្អ។<br>d) ក្នុងករណីបាញ់ថ្នាំៈ អ្នកបាញ់ថ្នាំ យ៉ាងហោចណាស់ ប្រើប្រាស់តែស្រោមដៃការពារ និងម៉ាសមាន គុណភាពល្អ។<br>e) មិនប្រើប្រាស់អ្វីទាំងអស់ដូចខាងលើ។ | ២<br><br>២<br><br>២<br><br>១ *<br><br>០ |
| ៣០ | សុខភាពនិងសុវត្ថិភាពកម្មករ | **ការលាងសម្អាត និងផ្លាស់ប្តូរ**<br>កំណត់ទីតាំងលាងសម្អាតឧបករណ៍ការពារខ្លួន )PPE) ការងូតទឹកសម្អាតខ្លួននិងការផ្លាស់ប្តូរអោយបានសមស្របចំពោះអ្នកបាញ់ថ្នាំបន្ទាប់ពីប្រើប្រាស់ថ្នាំ។ រាល់ឧបករណ៍ ការពារខ្លួន )PPE) ដែលប្រឡាក់ ក្នុងអំឡុងពេល | a) ពុំមានប្រើប្រាស់ថ្នាំពុលទេ<br>**ប្រសិនបើប្រើប្រាស់ថ្នាំពុលគឺ:**<br>b) កំណត់ទីតាំងសម្រាប់លាសម្អាត និងផ្លាស់ប្តូរគឺត្រូវ ( នៅដាច់ដោយឡែកពីប្រើប្រាស់លាងសម្អាតក្នុងគ្រួសារ។ | ២<br><br>២ |

| | | | | |
|---|---|---|---|---|
| | | ប្រើបាញ់ថ្នាំទាំងអស់គឺត្រូវលាងសម្អាត និងមិនត្រូវយកទៅដាក់ក្នុងផ្ទះឡើយ។<br>ទីតាំងដែលបានកំណត់នេះគឺត្រូវនៅដាច់ដោយឡែកពីកន្លែងប្រើប្រាស់លាងសម្អាតក្នុងគ្រួសារ។ | c)ទីតាំងដែលបានកំណត់សម្រាប់លាងសម្អាត និងផ្លាស់ប្តូរកន្លែងតែមួយ និងមិនមែនជាកន្លែងប្រើប្រាស់លាងសម្អាតក្នុងគ្រួសារទេ។<br>យទីតាំងលាងសម្អាត និងផ្លាស់ប្តូរអ្នកប្រើប្រាស់ថ្នាំ ( ពុល គឺប្រើប្រាស់ជាមួយការលាងសម្អាតក្នុងគ្រួសារដែរ។<br> | ១*<br>0 |
| ៣១ | សុខភាពនិងសុវត្ថិភាពកម្មករ | **បំរាមអ្នកប្រើប្រាស់ថ្នាំពុល**<br>ហាមមិនអោយប្រើប្រាស់ថ្នាំពុលចំពោះ៖ ស្រីមានផ្ទៃពោះ ឬ កំពុងបំបៅដោះកូន កុមារមានអាយុក្រោម១៨ឆ្នាំ ឬដោយមនុស្សដែលទទួលរងពីរុំារ៉ៃ ឬជំងឺផ្លូវដង្ហើម។ | a) មិនមានប្រើប្រាស់ថ្នាំពុល<br>**ប្រសិនបើប្រើប្រាស់ថ្នាំពុលគឺ៖**<br>b)ថ្នាំពុលមិនត្រូវបានប្រើប្រាស់ដោយ ស្រីមានផ្ទៃពោះ ឆ្នាំ១៨ឬ កំពុងបំបៅដោះកូន កុមារមានអាយុក្រោមឬដោយមនុស្សដែលទទួលរងពីរុំារ៉ៃ ឬជំងឺផ្លូវដង្ហើម។<br>c)ថ្នាំពុលត្រូវបានប្រើប្រាស់ដោយស្រីមានផ្ទៃពោះ ឬ ឆ្នាំ១៨កំពុងបំបៅដោះកូន កុមារមានអាយុក្រោមឬដោយមនុស្សដែលទទួលរងពីរុំារ៉ៃ ឬជំងឺផ្លូវដង្ហើម។<br> | ២<br>២*<br>0 |
| ៣២ | សុខភាពនិងសុវត្ថិ | **ពេលវេលាអាចចូលក្នុងស្រែវិញ** | a) ពុំមានការប្រើប្រាស់ថ្នាំកសិកម្ម | ២ |

| | | | | |
|---|---|---|---|---|
| | ភាពកម្មករ | **ពេលវេលាវិលចូលស្រែវិញបន្ទាប់ពីបាញ់ថ្នាំ៖**<br>១. អនុវត្តតាមការណែនាំនៅលើស្លាកផលិតផល ឬឬបន្ទាប់ពី៤៨ម៉ោង ប្រសិនបើមិនមានការណែនាំលើស្លាកសញ្ញា។<br>២. មានប្រាស្រ័យទាក់ទងគ្នាយ៉ាងច្បាស់លាស។ | ប្រសិនបើប្រើប្រាស់ថ្នាំ:<br>b) កសិករបំពេញលក្ខខណ្ឌទី១ និងលក្ខខណ្ឌទី២ ដោយផ្លាស់ប្តូរផ្លាក ឬ សញ្ញាហាមឃាត់នៅក្នុងស្រែ។<br>c) កសិករបំពេញលក្ខខណ្ឌទី១ និងលក្ខខណ្ឌទី២ ដោយប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ ពីពេលវេលាចូលស្រែវិញ។<br>d) កសិករមិនបានបំពេញលក្ខខណ្ឌទី១ និងទី២។<br> | <br>២<br><br>១ *<br><br>0 |
| ៣៣ | សុវត្ថិភាពអាហារ សុខភាពនិងសុវត្ថិភាពកម្មករ | **ការទុកដាក់ថ្នាំពុលកសិកម្ម និងជីគីមី**<br>ថ្នាំកសិកម្មនិងជីគីមី (រួមទាំងសំបកទទេ) គឺ៖<br>១. មានស្លាកសញ្ញាសម្គាល់<br>២. ទុកដាក់នៅក្នុងកន្លែងមានចាក់សោរដាច់ដោយឡែកពីប្រេងឥន្ទនៈ អាហារនិងផុតពីដៃក្មេង។ | a) មិនប្រើប្រាស់ទុកដាក់ថ្នាំកសិកម្មនិងជីគីមី<br>ប្រសិនបើមានការទុកថ្នាំពុលកសិកម្ម និងជីគីមីគឺ៖<br>b) កសិករបំពេញលក្ខខណ្ឌទី១ និងទី២<br>c) កសិករបំពេញលក្ខខណ្ឌទី២<br>d) មិនបានបំពេញលក្ខខណ្ឌខាងលើទាំងអស់<br> | ២<br><br>២<br>១ *<br>0 |
| ៣៤ | សុខភាពនិងសុវត្ថិភាពកម្មករ | **ការបោះចោលថ្នាំពុលកសិកម្ម**<br>សំបកថ្នាំពិលទទេ ថ្នាំនៅសល់ និងថ្នាំលេងប្រើប្រាស់ (ឧទាហរណ៍: ផុតអាយុប្រើប្រាស់ឬ ហាមឃាត់) គឺត្រូវបានបោះចោលត្រឹមត្រូវ តាមរយៈការប្រមូលផ្តុំ ប្រមូលត្រឡប់ យកមកវិញ ឬសេវាកម្មបោះចោលឬតាមរយៈការអនុវត្តល្អ ក្នុងការចោលថ្នាំកសិកម្ម។<br>ការអនុវត្តល្អក្នុងការបោះចោលថ្នាំពុលកសិកម្មរួមមាន៖ | a) មិនប្រើប្រាស់ថ្នាំកសិកម្ម<br>**ប្រសិនបើប្រើប្រាស់គឺ៖**<br>**b)** កសិករចូលរួមក្នុងការប្រមូល ឬ សេវាកម្មបោះចោល ជាពិសេសប្រសិនបើមានបរិមាណកាកសំណល់ច្រើន។ | ២<br><br>២ |

| | | | | |
|---|---|---|---|---|
| | | ១. សំបកទទេរគឺត្រូវលាងទឹក៣ដង។ ថ្នាំបាញ់និងទឹកកខ្វក់ ដែលនៅសល់គឺត្រូវចាក់ចោលក្នុងផ្នែកណាមួយកសិដ្ឋាន ឆ្ងាយពីប្រភពទឹកស្អាត។<br>២. សំបកថ្នាំ គេផលិតមិនអាចប្រើបានដោយដំបំបែកឬចាក់ ឲ្យប្រហោងមុនពេលយកទៅកបវានៅក្នុងស្រែ<br>៣.សំបកថ្នាំគឺត្រូវយកទៅកប់នៅកន្លែងកំណត់មួយយ៉ាងហោចណាស់ចំងាយ២០ម៉ែត្រពីប្រភពទឹកស្អាត) និងហាម ក្មេងចូលទៅជិត ឬ មនុស្សចូលទៅដោយគ្មានការអនុញ្ញាត។<br>៤. ថ្នាំពុលដែលឈប់ប្រើគឺត្រូវបញ្ជូនត្រឡប់ទៅអ្នកលក់ដើមវិញ ឬ ប្រសិនបើមិនអាចធ្វើបានទេ ការបោះចោលត្រូវធ្វើក្នុងលក្ខណៈមួយដែលកាត់បន្ថយផលប៉ះពាល់ដល់មនុស្សនិងបរិស្ថាន។ | c) ក្នុងករណីមិនសេវាកម្មនេះទេ កសិករត្រូវបំពេញតាមលក្ខខណ្ឌទាំង៤ក្នុងការអនុវត្តការបោះចោលថ្នាំពុលបានល្អ។ | ១ * |
| | | | d) ក្នុងករណីមិនមានសេវាកម្មនេះទេ កសិករមិនបានបំពេញតាមលក្ខខណ្ឌទាំង៤ក្នុងការអនុវត្តការបោះចោលថ្នាំពុលបានល្អ។ | ០ |
| | | | e) មានប្រព័ន្ធនៃការប្រមូលផ្តុំ បញ្ជូនទៅម្ចាស់ដើមវិញ ឬសេវាកម្មបោះចោល ប៉ុន្តែមិនប្រើប្រាស់។ | ០ |
| **សិទ្ធិការងារ** | | | | |
| ៣៥ | ពលកម្មកុមារ និការចូលរួមរបស់យុវជន | **ពលកម្មកុមារ**<br>កុមារអាយុក្រោម១៥ឆ្នាំមិនឲ្យធ្វើការងារជាកម្មករឡើយ។<br><br>សមាជិកគ្រួសារអាយុក្រោម១៥ឆ្នាំរស់នៅក្នុងកសិដ្ឋានគ្រួសារអាចចូលរួមក្នុងសកម្មភាពកសិកម្មដែលមានពន្លឺ ការងារណាដែលសមស្របតាមអាយុ ដែលផ្តល់នូវឱកាសឲ្យគេដើម្បីអភិវឌ្ឍន៍ជំនាញ ដែលមិនមែនជាសកម្មភាព៖<br>១. មិនបង្គគ្រោះថ្នាក់ដល់សុខភាព ការអភិវឌ្ឍរបស់កុមារ<br>២. មិនប៉ះពាល់ដល់ពេលវេលារៀនសូត្រ និងការកំសាន្ត។ | a) កសិករមិនជាប់ពាក់ព័ន្ធកុមារមានអាយុក្រោម១៥ឆ្នាំថាជាកម្មករឡើយ។ | ៣ |
| | | | b) សមាជិកគ្រួសាអាយុក្រោម១៥ឆ្នាំកំពុងរស់នៅ និងធ្វើការក្នុងកសិដ្ឋាន ហើយធ្វើតាមលក្ខខណ្ឌទាំង៤។ | ៣ * |
| | | | c) សមាជិកគ្រួសាអាយុក្រោម១៥ឆ្នាំកំពុងរស់នៅ និងធ្វើការក្នុងកសិដ្ឋាន ហើយមិនបានធ្វើតាមលក្ខខណ្ឌចាប់១ ឬ លើពីនេះទេ។ | ០ |

| | | | | |
|---|---|---|---|---|
| | | ៣. ស្ថិតក្រោមការឃ្លាំមើលពីមនុស្សធំ<br>៤. មិនធ្វើការលើសពី១៤ម៉ោងក្នុង១សប្តាហ៍ | d) កសិករមានជាប់ពាក់ព័ន្ធកុមារអាយុក្រោម១៥ (ដែលមិនមែនជាសមាជិកក្នុងគ្រួសាររស់នៅក្នុងកសិដ្ឋានទេ) ធ្វើជាកម្មករ។  | ០ |
| ៣៦ | ពលកម្មកុមារ និការចូលរួមរបស់យុវជន | **គ្រោះថ្នាក់ការងារ**<br><br>កម្មករត្រូវអនុវត្តតាមច្បាប់សុវត្ថិភាព ដែលត្រូវអនុវត្តនៅពេលបំពេញការងារ (ឧទាហរណ៍ ដូចជាត្រូវចូលក្នុងផ្ទះក្នុងករណីហានិភ័យផ្ទេកបន្ទោរ)។<br>កុមារអាយុក្រោ១៨ឆ្នាំមិនត្រូវឲ្យបំពេញការងារណាដែលអាចបង្កគ្រោះថ្នាក់ដល់សុខមាលភាព និងសុវត្ថិភាពរបស់ពួកគេឡើយ។<br>កុមារមានអាយុក្រោម១៨ឆ្នាំមិនត្រូវអនុវត្តការងារគ្រោះថ្នាក់ ឬការងារដែលគ្រោះថ្នាក់ផ្លូវកាយ ផ្លូវស្មារតីឬផ្លូវសីលធម៌របស់ពួកគេឡើយ។<br>ពួកគេមិនត្រូវធ្វើ៖<br>១. ការងារមិនស្ថិតនៅទីតាំងគ្រោះថ្នាក់<br>២. ការជាមួយគ្រឿងម៉ាស៊ីនដែលមានគ្រោះថ្នាក់ សម្ភារ និងឧបករណ៍ (ដូចបានកំណត់ក្នុងងច្បាប់ និងបទបញ្ញត្តិជាតិ<br>៣. ការងារផ្ទុកបន្ទុកធ្ងន់ធូរ<br>៤. ការងារមានសារជាតុបង្កគ្រោះថ្នាក់<br>៥. ការងារនៅពេលយប់<br>អាយុរបស់កម្មករត្រូវតែត្រួតពិនត្យ និងមានឯកសារបញ្ជាក់។ | a) ពុំមានកុមារអាយុក្រោម១៨ឆ្នាំធ្វើការនៅក្នុងកសិដ្ឋាន | គ្មាន |
| | | | b) មានកុមារអាយុក្រោម ១៨ឆ្នាំធ្វើការនៅក្នុងកសិដ្ឋានហើយកសិករអនុវត្តតាមល័ក្ខខណ្ឌទាំង៥។ | ៣* |
| | | | c) មានកុមារអាយុក្រោម ១៨ឆ្នាំធ្វើការនៅក្នុងកសិដ្ឋាន ហើយកសិករមិនអនុវត្តតាមលក្ខខណ្ឌមួយ ឬច្រើនលើពីនេះទេ។  | ០ |
| ៣៧ | ពលកម្មកុមារ និការចូលរួមរបស់យុវជន | **ការអប់រំ**<br><br>កុមារដែលរស់នៅក្នុងកសិដ្ឋានក្នុងអាយុសិក្សាត្រូវបានទៅរៀនពេញមួយឆ្នាំ។ | a) ពុំមានកុមារក្នុងអាយុត្រូវទៅរៀនរស់នៅក្នុងកសិដ្ឋាន | គ្មាន |
| | | | b) កុមារក្នុងអាយុត្រូវទៅរៀនដែលរស់នៅក្នុងកសិដ្ឋានបានទៅសាលារៀនពេញមួយឆ្នាំ | ៣ |

| | | | | |
|---|---|---|---|---|
| | | | c) កុមារក្នុងអាយុត្រូវទៅរៀនដែលរស់នៅក្នុងកសិដ្ឋាន បានទៅសាលារៀនប៉ុន្តែមិនបានពេញមួយឆ្នាំ<br><br>d) កុមារក្នុងអាយុត្រូវទៅរៀនដែលរស់នៅក្នុងកសិដ្ឋាន មិនបានទៅសាលារៀន ប៉ុន្តែមានកិច្ចខិតខំប្រឹងប្រែង ត្រូវបានធ្វើឡើងដើម្បីផ្តល់ការអប់រំ។<br><br>e) កុមារក្នុងអាយុត្រូវទៅរៀនដែលរស់នៅក្នុងកសិដ្ឋាន មិនបានទៅសាលារៀន និងមិនមានកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីផ្តល់ការអប់រំ។<br><br> | ២<br><br>១ *<br><br>០ |
| ៣៨ | មិនជាប់ពាក់ព័ន្ធ សូចនករវាយតម្លៃ SRPជាក់លាក់ | **ពលកម្មដោយបង្ខំ**<br><br>ពុំមានការបង្ខំកំលាំងពលកម្ម ពលកម្មក្នុងពន្ធនាគារឬពលកម្មដូចទាសភាព រួមមានការជួញដូរ និងពលកម្មជាប់បំណុល ជាប់ទោស ការជំរិតទារប្រាក់ការ គំរាមកំហែងការពិន័យឬការពិន័យ។<br>លក្ខខណ្ឌខាងក្រោមត្រូវបំពេញៈ<br>១. មិនមានការកាត់ទុក (ផ្នែកខ្លះ) ប្រាក់ខែ អត្ថប្រយោជន៍ ទ្រព្យសម្បត្តិ ឬឯកសារ (ឧទាហរណ៍: អត្តសញ្ញាណប័ណ្ណ និងឯកសារធ្វើដំណើរ) របស់កម្មករ ដើម្បីបង្ខំកម្មករដើម្បីបធ្វើការងារបន្តឡើយ។ | a) កសិករពុំជាប់ពាក់ព័ន្ធនឹងកម្មករទេ | គ្មាន |

| | | | | |
|---|---|---|---|---|
| | | ២ .ពុំមានការយកថ្លៃពីកម្មករសម្រាប់ការជ្រើសរើស ឬជួលឲ្យចូលធ្វើការដែលតម្រូវឲ្យកម្មករជាប់បំណុលរបស់កសិដ្ឋាន (ឬភ្នាក់ងារជ្រើសរើសបុគ្គលិក) ឡើយ។<br>៣. កម្មករត្រូវបានអនុញ្ញាតិឲ្យចេញពីបរិវេណកសិដ្ឋាននៅចប់វេនការងាររបស់ខ្លួន។<br>៤. ម៉ោងធ្វើការងារធម្មតារបស់កម្មករមិនលើសពី៤៨ម៉ោងក្នុងមួយសប្តាហ៍ឡើយ យ៉ាងហោចណាស់ឈប់សំរាកពេញ១ថ្ងៃក្នុងរយៈពេលធ្វើកា៦ថ្ងៃជាប់ៗគ្នាថ្ងៃធ្វើការ។<br>៥. ស្វាមី/ភរិយានិងកូនៗរបស់កម្មករជាប់កិច្ចសន្យាមិនត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងកសិដ្ឋាន។<br>៦ កសិដ្ឋានពុំចូលរួមឬអនុញ្ញាតិឲ្យមានការជួញដូរមនុស្សឡើយ។ | b) កសិករបង្ហាញការអនុវត្តតាមលក្ខខណ្ឌទាំង៦ចំណុចពេញលេញ។ (អ្នកពាក់ព័ន្ធនឹងបង្ហាញការអនុវត្តតាមដោយគ្មានឯកសារ)។<br>c) អនុវត្តមិនបានពេញលេញតាមល័ក្ខខ័ណ្ឌមួយឬច្រើនឡើយ។<br> | ៣*<br>0 |
| ៣៩ | សុខភាពកម្មករ និងសុវត្ថិភាពពលកម្មកុមារ និងការចូលរួមយុវជន ការផ្តល់សិទ្ធិដល់ស្ត្រី | **ការរើសអើង**<br>មិនមានការរើសអើង ឬ ការប្រព្រឹត្តដោយខ្វះការគោរពចំពោះកម្មករ និងសមាជិកគ្រួសាររបស់ពួកគេ។ លក្ខខ័ណ្ឌត្រូវអនុវត្តដូខាងក្រោម៖<br>១. មិនមានការរើសអើងផ្អែកលើយេនឌ័រ សាវតា សញ្ជាតិកំណើត សាសនា ពិការភាព និន្នាការភេទ ភាពមានផ្ទៃពោះ សមាជិភាពក្នុងអង្គការ និងគណបក្សនយោបាយ។<br>២. ពុំមានភាពខុសគ្នា ការបដិសេធ ឬ ចំណូលចិត្ត ប៉ះពាល់នឹងឱកាសស្មើគ្នា ប្រាក់កម្រៃ ការបណ្តុះបណ្តាល ភារកិច្ចការងារ អត្ថប្រយោជ៍ ប្រាក់រង្វាន់ការងារ ឡើងតួនាទី ការបញ្ឈប់ការងារ ការចូលនិវត្តន៍ ឬ ទាក់ទងនឹងការសម្រេចចិត្តលើការងារផ្សេងៗ។<br>៣. ពុំមានការងារទាក់ទងទៅនឹងការធ្វើតេស្តសុខភាព (លើកលែងតែការធ្វើតេស្តគ្រឿងញៀនស្របច្បាប់)។<br>៤. ពុំមានអប្បកិរិយា កាយវិការ ភាសារ ឬការប៉ះពាល់រាងកាយដែលមាន | a) កសិករមិនបានជួលកម្មករទេ<br>b) កសិករអនុវត្តតាមលក្ខណៈវិនិច្ឆ័យទាំង៥បានពេញលេញ(អ្នកពាក់ព័ន្ធនឹងបង្ហាញការអនុវត្តតាមដោយគ្មានឯកសារ)<br>c) កសិករមិនអនុវត្តតាមលក្ខណៈវិនិច្ឆ័យមួយឬច្រើនឡើយ។<br> | គ្មាន<br>៣*<br>0 |

| | | | | |
|---|---|---|---|---|
| | | លក្ខណៈរំលោភបំពានផ្លូវភេទ បង្ខិតបង្ខំ ឬគម្រាមកំហែងឡើយ។<br>៥. គ្មានការសម្លុតឬដាក់ទណ្ឌកម្មលើរូបកាយឡើយ។ | | |
| ៤០ | សុខភាពកម្មករ និងសុវត្ថិភាពពលកម្មកុមារ និងការចូលរួមយុវជន ការផ្តល់សិទ្ធិដល់ស្ត្រី | **សេរីភាពសមាគមន៍**<br><br>កម្មករមានសិទ្ធិក្នុងការបង្កើត ឬចូលរួម ក្នុងសមាគមន៍ ដែលពួកជ្រើសរើសដោយគ្មានការជ្រៀតជ្រែក និងចូលរួមជា ការចរចារជាសមូហភាពលើលក្ខខ័ណ្ឌការងារ<br>អនុវត្តតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖<br>១. កម្មករអាចបង្កើតនិងចូលរួមក្នុងអង្គការកម្មករ ទាំងខាងក្នុង(តំណាងកម្មករ) ទាំងខាងក្រៅ (តំណាងសហជីព) និងចូលរួមក្នុងការតវ៉ាជាសមូហភាពលើលក្ខខ័ណ្ឌការងារ<br>២. សមាគមន៍កម្មករ គឺត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពរបស់ខ្លួននៅក្នុងកសិដ្ឋាន ឬ ស្រែ<br>៣. មុខងាររបស់សមាគមន៍មិនត្រូវបានរារាំងហើយតំណាងសមាគន៍មិនត្រូវបានរើសអើង<br>៤. កសិករអនុវត្តន៍តាមកិច្ចព្រមព្រៀងដែលបានចរចារ។ | a) កសិករមិនមានប្រើប្រាស់កម្មករទេ<br><br>b) កសិករបង្ហាញការអនុវត្តតាមលក្ខណៈវិនិច្ឆ័យទាំង៤(អ្នកពាក់ព័ន្ធនឹងបង្ហាញការអនុវត្តតាមដោយគ្មានឯកសារ)<br><br>c) កសិករមិនអនុវត្តតាមលក្ខណៈវិនិច្ឆ័យមួយឬច្រើនឡើយ។<br><br> | គ្មាន<br><br>៣ *<br><br>0 |
| ៤១ | សុខភាពកម្មករ និងសុវត្ថិភាពពលកម្មកុមារ និងការ | **ប្រាក់ឈ្នួល** | a) កសិករមិនមានប្រើប្រាស់កម្មករទេ<br><br>b) កសិករបង្ហាញអនុវត្តពេញលេញតាមល័ក្ខខ័ណ្ឌទាំង៤ | គ្មាន<br><br>៣ * |

| | | | | |
|---|---|---|---|---|
| | ចូលរួមយុវជន ការផ្តល់សិទ្ធិដល់ស្ត្រី | ប្រាក់ឈ្នួល និងអត្ថប្រយោជន៍របស់កម្មករ៖<br><br>១. ប្រាក់ឈ្នួលរបស់កម្មករត្រូវឆ្លើយតប ឬលើសពីប្រាក់ខែអប្បរមាដែលតម្រូវក្រោមច្បាប់ក្នុងមូលដ្ឋាន និងច្បាប់ជាតិ។ ប្រសិនបើប្រាក់ឈ្នួលចរចាដោយស្ម័គ្រចិត្តរវាងនិយោជក និងសមាគមកម្មករ ចំនួនប្រាក់ឈ្នួលដែលបានចរចារ ត្រូវអនុវត្តចំពោះកម្មករទាំងអស់ គ្របដណ្តប់ក្រោមកិច្ចព្រមព្រៀងដែលបានចរចា។ នេះរួមបញ្ចូលទាំងការផ្តល់ប្រាក់ឈ្នួលស្មើគ្នាដល់បុរសនិងស្ត្រីសម្រាប់ការងារដែលមានតម្លៃស្មើគ្នា។<br><br>២. ប្រាក់ឈ្នួលត្រូវបង់ឱ្យទានពេលវេលា និងទៀងទាត់<br><br>៣. ប្រាក់ឈ្នួលត្រូវផ្តល់ឱ្យដោយរូបិយប័ណ្ណស្របច្បាប់ ឬ ក្នុងទម្រង់ដែលកម្មករអាចទទួលយកបាន។<br><br>៤. ការបន្ថែមម៉ោងការងារគឺជាការស្ម័គ្រចិត្ត និងត្រូវផ្តល់ប្រាក់តាមការចរចារួមគ្នា ទៅតាមអត្រាដែលទាមទារដោយច្បាប់ជាតិ។ | c) កសិករបង្ហាញពីការអនុលោមបានតិចតួចនិង / ឬ មិនអនុវត្តតាមលក្ខណៈវិនិច្ឆ័យមួយឬច្រើនឡើយ។<br><br> | 0 |